# ការសំភាសន៍របស់អ៊ុំស្រី យ៉ាន់ ចន្ធូ

កៈ អ្នកដែលសំភាសន៍ឈ្មោះញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍យ៉ាន់ ចន្ធូ

## ការសង្ខេបរបស់អ៊ុំស្រី យ៉ាន់ ចន្ធូ

អ៊ុំស្រីយ៉ាន់ ចន្ធូ ជាអ្នកស្រុកស្អាង ជាស្រុកដែលធ្វើចំការ ហើយគាត់នឹងគ្រួសារតាំងពីដើមមកគឺធ្វើរបរស្រែចំការ ហើយ គាត់រស់នៅដោយរីករាយជាមួយបងប្អូនគាត់ ហើយបងប្អូនគាត់ស្រលាញ់គ្នាណាស់ ហើយម្តាយឪពុកគាត់គឺស្រលាញ់កូនចៅ អ្នកមីងបានប្រាប់ថាកាលយាយរបស់គាត់គឺល្អណាស់ហើយបានលាក់ស្ករនឹងអំបិលសំរាប់ពេលនៅក្នុងជំនាន់ប៉ុល ពតអ៊ីចឹងធ្វើអោយកូនៗដែលនៅជាមួយមានអ្វីទាំងអស់ហ្នឹងទុកហូប។ សព្វថ្ងៃអ្នកមីងបានដាំផ្សីនៅផ្ទះទុកសំរាប់ចិញ្ចឹមជីវិត។ អ្នកមីងគាត់កើតមកទាន់យាយតាខាងឪពុកម្តាយស្ទើរតែទាំងអស់អត់តែតាមួយព្រោះគាត់ស្លាប់តាំងពីម្តាយគាត់នៅក្មេងហើយគាត់ពុំទាន់កើត។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំស្រីដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់របស់អ៊ុំស្រីអ្នកខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ៊ុំស្រីនៅក្នុងថ្ងៃនេះ ហើយថ្ងៃដែលពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨។ ការសំភាសន៍នេះមានទីតាំងស្ថិតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា ហើយអញ្ចឹងនាងខ្ញុំសូមចាប់ផ្តើមសួរអំពីជីវប្រវត្តិរបស់អ៊ុំដូចតទៅ អ៊ីចឹងអ៊ុំសូមប្រាប់ឈ្មោះឈ្មោះអីគេដែរ?

ខៈ ញ៉ុមឈ្មោះ យ៉ាន់ ចន្ធូ។

កៈចាំអញ្ចឹងអ៊ុំសំរាប់សព្វថ្ងៃអ៊ុំអាយុប៉ុន្មានហើយ?

ខៈញ៉ុមអាយុ៥៥។

កះអញ្ចឹងប្អូនម៉ែញុំមទេអីចឹង?

ខះចាំ!!

កះអញ្ចឹងហៅមីងវិញអញ្ចឹង!!អីចឹងអ្នកមីងសំរាប់អើរសព្វថ្ងៃក្រៅពីឈ្មោះចន្ទ មានអ្នកណាគេដាក់ឈ្មោះមីងអីផ្សេងទៀតទេ?

ខះ អត់ទេ!!

កះ គេហៅតែមួយហ្នឹងទេហេ?

ខះ ចាំ!!

កះដូចពីក្មេងមកឧទាហរណ៍ដូចថាក្នុងក្រុមគ្រួសារអីចឹង?

ខះ មានតែឈ្មោះហ្នឹងតែប៉ុណ្ណឹង ពីអើយមក។

កះតែគេអត់មានដាក់រហ័សនាមអោយឬក៏ហៅងារអីទេ?

ខះ អត់មានទេ អត់មានងារអីទេ។

កះ ហើយអញ្ចឹងល្អអញ្ចឹង !!អ្នកខ្លះពេលខ្លះនៅស្រុកខ្មែរយើងភាគច្រើនគេរកតែនេះរកងាររកអីដាក់អោយកូនទេអំណាស់!!ចាំ!!ច្រឡំតែហៅអំរហូត!!អូខេអីចឹងអ្នកមីងសំរាប់ឆ្នាំខ្មែរកើតឆ្នាំអីគេដែរ?

ខះ ឆ្នាំខ្មែរហេ?

កះចាំ!!

ខះឆ្នាំថោះ!!!

កះចាំឆ្នាំថោះ!!ហ្នឹងហើយសត្វទន្សាយ!!

ខះចាំ!!

កះហ្នឹងហើយ អ្នកមីងថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងទេ?

ខ៖ ចាំតែឆ្នាំ!!

ក៖ឆ្នាំប៉ុន្មានវិញ?

ខ៖ ឆ្នាំ៦២ ១៩៦២ !!

ក៖ហ្ហ៎ទឹមតែឥឡូវៗហាមុនលន់ នល់!!អូខែអញ្ចឹងមើលនៅក្នុងសំបុត្រកំនើតរបស់អ្នកមីង អ្នកមីងកើតថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦២។

ខ៖ចាំ!!

ក៖ នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា។នៅហ្នឹងម៉ងអ្នកមីងណោះ?

ខ៖ចាំ!!

ក៖កើតមកដីអីនៅហ្នឹងហេ?

ខ៖ស្រុកកំណើតនៅហ្នឹងនៅក្រោមវត្តឈ្វងលៀបកាលកើតហាំ!!

ក៖ចាំ!!

ខ៖ហ្នឹងនៅតែស្រុកជាមួយគ្នាហ្នឹងបើឃុំរកាខ្ពស់។

ក៖ កោះគរដូចគ្នា។

ខ៖ កោះគរដូចគ្នា។

ក៖អ៊ីចឹងម៉េចបានមកដូរនៅនេះ?

ខ៖ ពេលមុននៅភូមិព្រៃកថី!!

ក៖ចាំ!!

ខ៖ខាងណោះវត្តហាំ ភូមិព្រៃកថី អានេះភូមិកោះគរ។

ក៖ តែដល់ពេលកើតកើតនៅភូមិព្រៃកថីណោះទេហី?

ខ៖ ចាំ!!កាលកើតនៅភូមិព្រៃកថី ឃុំរកាខ្ពស់។

ក៖ ចាំអីចឹងគ្រាន់តែខុសភូមិទេ!!

ខ៖ ចាំស្រុកកំណើតដូចតែស្រុកកំនើតយើងនៅហ្នឹងដែរហ្នឹង។

ក៖ ចាំមួយកោះគរ មួយព្រៃកថី។

ខ៖ ព្រៃកថី ចាំ!!

ក៖ ចាំ អញ្ចឹងអ៊ំស្រីសំរាប់អ៊ំស្រីមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ឥឡូវនៅសល់៧នាក់។

ក៖ ចុះបើសិនជាអត់ទាន់មាន៧នាក់ហ្នឹងប៉ុន្មានទៅវិញ?

ខ៖ ១២។

ក៖ អូយច្រើនណាស់!!

ខ៖ ម៉ែញុំមកូនមួយឡូ!!

ក៖ មួយឡូ!!

ខ៖ ប៉ុន្តែស្លាប់អស់ខ្លះហើយ!

ក៖ គាត់ស្លាប់មូលហេតុអីគេដែរអ៊ំ?

ខ៖ ខ្លះ គាត់នៅពីទូចអ៊ិចឹងស្លាប់ទៅណាស់!!

ក៖ចាំ!!

ខ៖ហើយបងញុំមនោះគាត់កូន៥ ៦ហើយទឹមតែស្លាប់ដែរ។

ក៖ មានអ្នកណាគេស្លាប់នៅក្នុងសង្គ្រាមអីអត់?

ខ៖ មាន
មាននៅពីទូចហ្នឹងដែលញ៉ុមនិយាយកើតបានមកនៅទូចៗហ្នឹងគាត់ស្លាប់ហើយណាស់!!

ក៖ ចាំហ្នឹងហើយ!!

ខ៖ កូនគាត់កើតហើយបានឈឺស្លាប់អីអញ្ចឹងទៅ!!តែស្លាប់ហ្នឹងនៅទូចៗទេណាស់!!

ក៖ចាំ!!

ខ៖ឥឡូវហ្នឹងនៅ៧នាក់។

ក៖ ឥឡូវអ្នកមីងសំរាប់បងប្អូនទាំង១២ អ្នកមីងចាំឈ្មោះពួកគាត់ទាំងអស់ទេ?

ខ៖ ខ្លះមិនទាន់បានដាក់ឈ្មោះផងស្លាប់ទៅវិញ!!

ក៖ ឥឡូវ!!

ខ៖ ចាំតែបងញ៉ុមមួយ!!

ក៖ចាំ!!

ខ៖ បងយ៉ានបងគេ។

ក៖
ចាំឥឡូវអ្នកមីងរៀបរាប់ឈ្មោះទាំង១២នាក់ហ្នឹងមើលចាំអ្នកណាគេប្រាប់មួយហ្នឹងតែបើសិនជាភ្លេចក៏អត់ដឹងធ្វើម៉េចដែរ អ្នកខ្លះអត់ទាន់មានឈ្មោះស្លាប់!!!

ខ៖ ចាំ!!ហ្នឹងរាប់អ្នកស្លាប់ហោ?

ក៖ទាំងអស់ម៉ងទាំងរស់ទាំងស្លាប់!!

ខ៖ ទាំងអស់ហោ?

ក៖ចាំ!!

ខ៖ទីមួយឈ្មោះបងយ៉ាន !!

កះចាំ!!

ខះទី២ឈ្មោះបងនី ហើយទី៣ខ្ញុំ ហើយទី៤គន្ធា !!

កះឈ្មោះដូចញ៉ុមទៀត!!

ខះ គន្ធា គន្ធាហ្នឹងគេទៅវិហារដែរតើ!!

កះ តែឥឡូវឈប់វិញហើយហោ?

ខះ គេផ្អាកគេ ហើយអើរបន្ទាប់មកជៀប ជៀបហើយសុខលាងប្រុស ហើយសុខលី។

កះចាំ!

ខះប្រុសដែរ។ហើយបាន៧ ប្អូន៧ហាំ!!

កះ ចាំឈ្មោះ៧?

ខះចាំ!!

កះតែប៉ុណ្ណឹង ?

ខះ ហើយនឹងអ្នកស្លាប់ហ្នឹងអត់ស្គាល់ឈ្មោះ។ឈ្មោះដារ៉ាមួយអ្នកស្លាប់ហាំ!!

កះចាំ!!

ខះប្អូនបន្ទាប់ញ៉ុមស្លាប់ហ្នឹងហាំ!!!

កះ អ៊ីចឹងមីងយៀបប្អូនរបស់មីងទេអ៊ីចឹង?

ខះ យៀបប្អូន។

កះ អើ ញ៉ុមអត់ដឹងផង។

ខះ ប្អូនបង្កើតទៅវិហារហ្នឹងបងប្អូនបង្កើត!!

កះ ចាំហ្នឹងហើយ។

ខ៖ បានទៅវិហារយើងមិន៣នាក់បងប្អូន នាំបងប្អូនបានទៅ៣នាក់ ហើយគន្ធាហ្នឹងស្រាប់តែគេម៉េចគេគេផ្អាកទៅ។

ក៖ អត់ដឹងពីមូលហេតុទេអ្នកមីងណេះ?

ខ៖ ហេទៅដូចថាវាមើលអក្សរមើលមិនរួច ទៅមើលមិនឃើញ ហើយទៅអង្គុយតែស្តាប់គេម៉ង់ៗវាអៀនខ្លួនហាំ!!ទៅហាំវានិយាយអីចឹងហា!!

ក៖ទៅគិតអីចឹងអត់កើតទេ!!

ខ៖គិតអីចឹង !!ញ៉ុមគិតខុសវាបើញ៉ុមមើលអត់ឃើញមើលអត់រួចក៏ញ៉ុមទៅស្តាប់គេដែរ ១០ម៉េចក៏ចាំ៤ ៥ដែរបងណាស់!!

(មិត្តភក្តិ)៖ ដល់ថ្ងៃចុងក្រោយដឹរិចម៉ងអ្នកអត់ចេះហ្នឹង!!

ក៖អោយតែខំប្រឹងអ្នកមីង!!

(មិត្តភក្តិ)៖ ព្រះអង្គជួយម៉ង!!

ខ៖ ចេះតែទៅស្តាប់ជាមួយគេយើងមើលមិនរួចយើងអោយគេមើលទៅ!! ពីគម្ពីរអីយើងស្តាប់គេទៅ!!

(មិត្តភក្តិ) ៖គន្ធាហ្នឹងហាថ្ងៃក្រោយទៅជួយយើងឌឺរិចម៉ង!!ព្រោះយើងអត់ចេះអក្សរ!!

ក៖តែយើងក៏ត្រូវតែព្យាយាមដែរអ្នកមីងណាស់!!

(មិត្តភក្តិ)៖ ហើយយើងចេះតែខំខ្លះៗទៅ!!

ខ៖
មើលរួចដែរហ្នឹងប៉ុន្តែគ្រាន់តែអារបៀបយើងមើលចេះតិចដែរអញ្ចឹងយើងមើលភ្នែកអន់តិចទៅរឹតតែយ៉ាប់មើល!! ញ៉ុមមើល ញ៉ុមបានរៀនឯណាជំនាន់អាពតអត់បានរៀនទេ បានរៀនការហើយរៀនអក្ខរកម្មទេបានចេះខ្លះហ្នឹងហាំ!! បងនៅអាពតមានបានរៀនណា អាយើងពេញរៀនគេអោយទៅរែកដីហ្នំ!!

(មិត្តភក្តិ)៖ ហ្នឹងហើយ!!

ខ៖ ទៅលើកដីទៅរែកដីនៅណោះ!!នៅធន់មន្តហ្នំ!!

ក៖ វត្តធន់មន្តហោ?

ខ៖ ហ្នឹងហើយចាំ ហ្នឹងជីកប្រឡាយលើកទំនប់នៅហ្នឹង!!!

ក៖ចាំ!!

ខ៖ហើយបើបងញ៉ុមទូលក្រសាំងហ្នឹងអាផ្លូវយើងហ្នឹង!!បងៗញ៉ុមរែកដីនៅអាទំនប់ទូលក្រសាំងហ្នឹង។

ក៖អាផ្លូវយើងរាល់ថ្ងៃហ្នឹង!!

ខ៖ អាផ្លូវយើងជិះរាល់ថ្ងៃហ្នឹង ចាំ!!

ក៖ ហ្នឹងញ៉ុមឮពួផល្លីហ្នឹងសុទ្ធតែអ្នកកាប់ដាក់នៅហ្នឹងហើយ!!

ខ៖ ហ្នឹងហើយសុទ្ធតែជំនាន់ ជំនាន់បងញ៉ុមបន្ទាប់ៗញ៉ុមហ្នឹងហាំ!!

ក៖ គេថាធ្វើហ្នឹងលឿនសាហាវណាស់មីងហី!!

ខ៖ នៅហ្នឹងសាហាវណាស់រែកដីណា យកទៅវ៉ៃចោលក៏វ៉ៃចោល
អាណាខ្ជិលអីយកទៅវ៉ៃចោលនៅកោះគរហ្នឹង។

(មិត្តភក្តិ)៖ និយាយថាកោះគរហ្នឹងទីហ្នឹងហោ?

ខ៖ កោះគរហ្នឹងទល់មុខហ្នឹងបង!!ទល់មុខ !!

ក៖ ឆ្លងទៅ!!

ខ៖ កោះហ្នឹង!! កោះហ្នឹងវែងដែរតើ!!

ក៖ អ៊ីចឹងអ្នកមីងទៅម្ខាងទៀតទន្លេមួយទៀតមែន?

ខ៖ ទន្លេមួយទៀត!!

ក៖ ហ្នឹងកោះ!!

ខ៖ កោះហ្នឹងយើងឆ្លងទៅកោះហើយមានកោះនៅខាងណោះមួយទៀត!!

ក៖ហ្ន៎!!!!

(មិត្តភក្តិ)៖ហ៊ីទំនងសប្បាយណាស់!!

ខ៖ កោះនេះ កោះគេនៅកណ្តាលហា៎!!

ក៖ចា៎!!

ខ៖ ឥឡូវគេហៅកោះរំដួលទេ!!យើងហ្នឹងបានគេហៅកោះគរ!!

(មិត្តភក្តិ)៖ គេដូរ!!

ខ៖ ចា៎ឥឡូវគេដូរហើយ គេហៅភូមិកោះរំដួល!!ឥឡូវហា៎នៅកន្លែងកោះគរឥឡូវហា៎!!

ក៖ គេដូរយូរនៅអ្នកមីង ?

ខ៖ គេទឹមតែដូរដែរដូចទឹមយើងប្រកាសដូរយើងមួយឆ្នាំពីរហ្នឹង!!

(មិត្តភក្តិ)៖ ដូចដូរដូចកំពង់សោមអីអញ្ចឹង គេដូរ!!ផ្លាស់ក្រុង!!

ក៖ ផ្លាស់ប្តូររដ្ឋបាលខាងភូមិបាល!!
អ្នកមីងដូចជាបងប្អូនអ្នកមីងឥឡូវដូចជាគាត់នៅរស់៧នាក់ហ្នឹងហោ?

ខ៖ចា៎!!

ក៖ គាត់ប្រកបរបរអីគេដែរមីងចិញ្ចឹមជីវិតរាល់ថ្ងៃ?

ខ៖ ខ្លះធ្វើចំការ ខ្លះធ្វើរោងចក្រ!!

ក៖ចា៎!!

ខ៖ ខ្លះលក់ដូរ!!

ក៖ នៅផ្ទះអីអញ្ចឹងទៅហី?

ខ៖ ចាំដូចញ៉ុមអីអញ្ចឹងដាំចំការអីអញ្ចឹងទៅហើយប្អូនៗហ្នឹងខ្លះក៏ធ្វើចំការ លក់ដូរខ្លួនឯងអីខ្លះៗអីចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ខ្លះទៅធ្វើការងាររោងចក្រ។

ក៖ចាំអីចឹងបងប្អូននៅគាត់នៅកោះគរហ្នឹងនៅជាមួយគ្នាឬក៏មានអ្នកណាបែកទៅណាខ្លះ?

ខ៖ នៅទាំងអស់ នៅមូលគ្នាហ្នឹង!!

ក៖ ចាំនៅចែកដីមួយឡូត៍មួយឡូត៍ម្នាក់អីចឹងទៅហោ?

ខ៖ ចាំនៅដីភូមិហ្នឹង ខ្លះអត់មានមានចែក នៅជំនាន់ញ៉ុមបានមានដីចែក។

ក៖ចាំ!!

ខ៖ជំនាន់ញ៉ុមហ្នឹងដីអស់ហ្នឹងសុទ្ធតែចែកអោយយើងយើងអត់បានទិញទេ
យើងការកាលទាន់ដីនៅហ្នំ!!ដល់ពេលចែកអាជំនាន់យើងអស់
ដល់ពេលអាជំនាន់ប្អូនៗយើងនឹងអត់មានទេម៉ែឪចែកអោយទេ!!

(មិត្តភក្តិ)៖ ដូចញ៉ុមអីចឹងដែរ អ្នកក្រោយៗអត់មានទេ!!

ក៖ ហ្នំអីចឹងអ្នកមីងគ្រាន់តែបែកពីប៉ុល ពតមកការ?

ខ៖ ចាំញ៉ុមការ៧៩(១៩៧៩)។

ក៖ ហ្នំដល់ពេលអីចឹងគេចែដីអោយម៉ង?

ខ៖ មានដី!!មានដីចែកអោយគ្រប់គ្នា អោយតែការជំនាន់ហ្នឹងមានដីចែកអោយហាំ!!

ក៖ចាំ!!

ខ៖
ហើយដល់អ្នកក្រោយៗគេចែកហើយអស់ហើយអត់មានដីចែកទេ!!ម៉ែឪហ្នឹងចែកអោយទៅ!!

កះទាល់តែយកលុយទិញបានបាន។

ខះ ទាល់តែមានលុយទិញ បើអត់មានលុយទិញហ្នឹង
ម៉ែហ្នឹងហាំចេះតែចែកអោយកូននៅទៅ។

កះ ចាំវាត្រូវតែតៗគ្នាអ៊ីចឹងហើយអ្នកមីង!!!!

ខះចាំ!!

កះចាំ!!

ខះ ធ្វើម៉េចបើជំនាន់វាអស់ដីចែកហើយ។

កះ អ្នកមីងពេលក្មេងចូលចិត្តលេងអីគេជាមួយបងប្អូន?ចាំទេ?

ខះ មិនដឹងលេងអីទេជាមួយបងប្អូន!!

(មិត្តភក្តិ)៖ ដូចលេងបាយខុមបាយអី!!

ខះ ហ្នឹងហើយលេងតើលេងបាយខុម !!ការពិតកាលនៅពីក្មេងលេងកៅស៊ូ
លេងផ្ទាត់កៅស៊ូហ្នំបង!!

កះ ផ្ទាត់អាកៅស៊ូឆ្ពឹះកងហ្នឹងអ៊ំហេ?

ខះ ហ្នឹងហើយអាឆ្ពឹះចូលវង់ហ្នំ!!

កះចាំ!!

ខះ កាលហ្នឹងគូរវង់អ៊ីចឹងទៅណាស់!!

(មិត្តភក្តិ)៖ ញ៉ុមលេងអ៊ីចឹងដែរ!!

ខះ ដាក់១០ម្នាក់២០ម្នាក់អ៊ីចឹងទៅ
អ្នកណាឆ្ពឹះបានច្រើនក្នុងវង់អ្នកហ្នឹងបានលុយហើយហាអ្នកហ្នឹងបានកៅស៊ូច្រើនហើយ!!

(មិត្តភក្តិ)៖ ភ្លេចបាយភ្លេចទឹកលេងអាហ្នឹងហាំ!!

ខ៖ ហ្នឹងហើយរក់លេងតែអាហ្នឹង!!

ក៖ ទាំងបងប្អូនគ្នាអីទាំងអស់ហ្នឹងហោ?

ខ៖ ហ្នឹងហើយចាំ!!

ក៖ មានអ្នកណាធ្លាប់ព្រួតគ្នានាំគ្នាកោរអីទេ?ភាគច្រើនលេងអីវ៉ាន់ភាគច្រើនព្រួតគ្នាកោរអីវ៉ាន់!!

(មិត្តភក្តិ)៖ កាលហ្នឹង អត់ចេះកោរទេ!!

ខ៖កាលហ្នឹងព្រួតគ្នាអត់កោរទេធំៗណាស់!!ដឹងតែផ្ទាត់បានប៉ុន្មានយកតាមសមត្ថភាពរៀងខ្លួនបានប៉ុណ្ណឹង!!

(មិត្តភក្តិ)៖ ហើយមានអាផ្តុំទៀតគន្ទាហាំ!!

ក៖ ផ្តុំហ៊ុយដីហ្នឹង?

(មិត្តភក្តិ)៖
ផ្តុំហើយចូលហើយនេះវាពាក់លើគ្នាទៅ!!អាហ្នឹងឈ្នះហើយយកមួយមកមកផ្តុំទៀត!!

ក៖ សប្បាយណាស់អ៊ំពេលហ្នឹងអ៊ីចឹងហោ?

ខ៖ ហ្នឹងហើយ!!

ក៖ អ៊ំនៅពីក្មេងមកដូចរកភាគច្រើនដូចនៅផ្ទះអីវ៉ាន់
ក្មេងៗមានដូចជួយធ្វើការនៅផ្ទះអីខ្លះអីអត់?ទាំងបងប្អូនអីវ៉ាន់ហាំដូចមានដាំអីដាំអីទេ?

ខ៖ ដាំតើម៉ែគាត់ធ្វើចំការដែរកាលហ្នឹងហាំ
គាត់ធ្វើស្រូវគាត់ដាំម្រេះដាំអីអញ្ចឹងទៅ!!ហើយធ្វើដាំពោត គ្រប់ គ្រសក់អីអញ្ចឹងទៅ!!

ក៖ចាំ!!

ខ៖យើងជួយបេះជួយអីគាត់អញ្ចឹង អីអញ្ចឹងទៅ គាត់ធ្វើអីយើងជួយធ្វើហ្នឹងទៅ!!

ក៖ចាំទាំងបងប្អូនទាំងអីទាំងអស់ហ្នឹងអ៊ំហី?

ខ៖ ចាំ!!ទាំងបងប្អូនទាំងអីទាំងអស់កាលហ្នឹងញ៉ុមអត់ទាន់ការទេណាស់!!

ក៖ចាំ!!

ខ៖យើងនៅមូលគ្នាអញ្ចឹងណាស់ ហើយគាត់ដាំដំនាំអីអញ្ចឹងទៅ!! បងប្អូនហ្នឹងទៅជួយទៅជួយគាត់ហាំ!!

ក៖ចាំ!!

ខ៖ធ្វើស្រូវធ្វើអីចេះតែជួយធ្វើទៅ!! ច្រូតស្រូវច្រូតអីជាមួយគ្នាហ្នឹង!!

ក៖ ពីដើមដីច្រើនណាស់អ៊ំហោ?

ខ៖ ចាំពីដើមដីច្រើន!!

(មិត្តភក្តិ)៖ ខ្វះអីដីពីដើម!!មានគ្រាន់តែធ្វើចំការ!!

ក៖ ម្នាក់ៗសុទ្ធតែមានរាប់ហិចតាហើយហោ?

ខ៖
ឥឡូវក៏មានដែរនៅចុងព្រៃកចីហ្នឹង!!ប៉ុន្តែម៉ែញ៉ុមអីគាត់ចាស់ៗទៅគាត់ចែកអោយកូនទៅណាស់!!

ក៖ចាំ!!

ខ៖ហើយដីហ្នឹងកូនគេធ្វើរោងចក្ររោងអី ឥឡូវនៅចោលហ្នឹងទៅ!!

ក៖ តែអត់មានអ្នកណាគេធ្វើអីធ្វើអីទេហោ?

ខ៖ហ្នឹង!!

ក៖អញ្ចឹងអ៊ំអាព្រៃកចីហ្នឹង ឆ្លងទៅអាខាងណោះម្ខាងទៀតឬក៏ម៉េចឬក៏ទៅផ្លូវ?

ខ៖ នៅខាងត្បូងវត្តនេះ!!ជិះតាមផ្លូវនេះអញ្ចឹងទៅ ខាងត្បូវវត្តឈូងលៀបហ្នឹង!!

ក៖ ត្បូងតាមផ្លូវទួលក្រសាំងហ្នឹងដែរហោ?

ខ៖ ផ្លូវមកពីទួលក្រសាំងនៅវត្តហ្នឹង មានផ្លូវគេកាច់ទៅឯជើង ត្បូងទៅទៀតទៅណាស់ ទៅព្រៃកគូចព្រៃកអីអញ្ចឹងទៅ!!

ក៖ចាំ!!

ខ៖ហើយយើងទៅដល់ហ្នឹងស្ពានព្រៃកថីហ្នឹង!!

(មិត្តភក្តិ)៖ និយាយធូនៅនេះដីមួយឡូត៏ប៉ុន្មានដី?

ខ៖ថ្លៃដែរហ្នឹងបង!!

(មិត្តភក្តិ)៖ ប៉ុន្មានម៉ឺន?

ក៖ ដីនេះសុទ្ធតែរ៉ាប់ម៉ឺន!!

ខ៖ ដីតាមទូចតាមធំ សុទ្ធតែម៉ឺនហើយ!!

ក៖តែដីចោលនោះដូចអត់មានលក់អត់មានអីដែរហោ?

ខ៖ ញ៉ុមហោ?

ក៖ចាំទុកចោលនៅហ្នឹងទៅអ៊ំហោ?

ខ៖ ដីញ៉ុមព្រៃកថីហ្នឹងហោ?

ក៖ហ្នឹងហើយ!!

ខ៖ គេរកតែទិញដែរហ្នឹងតែឥឡូវធ្លាក់ទៅប្អូនៗញ៉ុមហើយញ៉ុមអត់បានទេ!!

ក៖ហ្ហ៎!!

ខ៖ម៉ែគាត់ចែកអោយប្អូនៗព្រោះប្អូនៗក្រោយគ្នាអត់មានបានចែកដីពីរដ្ឋចែកអោយដូចញ៉ុមទេណាស់!!

(មិត្តភក្តិ)៖ ថ្លៃតែមួយឡូត៏ប៉ុន្មានម៉ឺន អត់ដឹងដែរហោ?

ខ៖ វាអត់មានដីលក់ទៀតហ្នឹងណាបង!!

កះ ដល់ពេលអញ្ចឹងអត់ដឹងទៅអ៊ំណេះ?

ខះ ចាំ!!ដល់អញ្ចឹងអត់ដឹង!!

(មិត្តភក្តិ)៖ ថ្លៃក្រេលៗអ៊ីចឹងដែរ!!

ខះចាំ!!!

(មិត្តភក្តិ)៖ ៣ ៥ម៉ឺនអីអញ្ចឹងទៅ!!ខះចាំ!!

កះអ៊ំដល់ពេលអើរនិយាយថាជាមួយបងប្អូនហាំ!!ការពេលបែកប៉ុល
ពតហើយបានរៀបការអស់ៗទៅអ៊ំហេ?

ខះ គាត់ ដល់ពេលបែកប៉ុល ពតហើយបានវាការគ្រប់គ្នាហ្នឹងហាំ!!

កះមុនអាពតអត់មានអ្នកណាគេការអីមួយទេហេ?

ខះ អត់ទេ ដល់តែបែកអាពតហើយបានការបងញ៉ុមអីហ្នឹង
បងញ៉ុមបែកអាពតហើយភ្លាមហ្នឹងការ !!

កះចាំ!!

ខះ ការ៧៩(១៩៧៩) ជិត៨០ហើយ(១៩៨០)!!កះចាំ!!

(មិត្តភក្តិ)៖ ការស្រេករញ៉ុមដែរ!!

ខះញ៉ុមការឆ្នាំរក។

កះឆ្នាំរកហេ??ហើយអ៊ំបងប្អូនដែលនៅជាមួយអ៊ំហ្នឹងដូចជា
អ៊ំចូលចិត្តលេងជាមួយអ្នកណាគេ?

ខះ បងប្អូនដែលនៅស្រេករៗគ្នាមានតែញ៉ុមនឹងបន្ទាប់ញ៉ុម
បន្ទាប់គ្នាហ្នឹងហាំ!!ចូលចិត្តលេងណាស់ជាមួយគាត់ហ្នឹងមើលគោក៏តែពីរនាក់ហ្នឹងដែរអាបងប
ង្អស់នោះគាត់អត់សូវលេងជាមួយយើងទេ
គាត់ដល់អាយុគាត់ចូលដល់សាលារៀនអីអ៊ីចឹងទៅណាស់!!

ក៖ចាំ!!

ខ៖ គាត់អត់សូវបានលេងជាមួយ។

ក៖ លេងតែជាមួយបងបន្ទាប់?

ខ៖
លេងតែបងបន្ទាប់ញ៉ុមបងនីហ្នឹងទៅណាទៅតែជាមួយបងទៅមើលគោអីតែជាមួយគ្នាអីអញ្ចឹងទៅណាស់!!

ក៖ចាំឥឡូវគាត់នៅរស់ដល់សព្វថ្ងៃហោ?

ខ៖ នៅតើ!!

ក៖ នៅជិតៗហ្នឹងដែរអ៊ំហោ?

ខ៖ នៅណោះនៅជិតផ្ទះម៉ែញ៉ុមខាងត្បូងជិតវត្តហ្នឹង!!

ក៖ ជិតឈ្វេងលៀបហ្នឹងហោ?

ខ៖ ចាំ!!

ក៖ចាំ!!

ខ៖មកណោះតែញ៉ុមទេ បងប្អូនជិតគ្នានៅជិតម៉ែហ្នុំ!!

ក៖ចាំ!!

ខ៖ ព្រោះអីគេចែកដីអោយញ៉ុមនៅហ្នឹងនោះ!!

ក៖ ហ៊ើៗ!!អ៊ីចឹងអ៊ំស្រីចូលដល់ម្ដាយអ៊ំវិញម្ដងម្ដាយអ៊ំគាត់ឈ្មោះអីគេដែរ?

ខ៖ កៅ ជា!!

ក៖ កៅជា?

ខ៖ចាំ!!

កះ ហាំ!!តែម៉េចនៅក្នុងសំបុត្រកំណើតគេដាក់យ៉ាន់ ចន្ទវិញ?

ខះ ហ្នឹងគេដាក់ខុសអោយញ៉ុមច្រឡំ ហ្នឹងគេកត់អោយហ្នឹងគេកត់អោយខុសតែម្តង!!

កះចាំ!!

ខះមិនយកត្រកូលម៉ែញ៉ុមទៅដាក់ទៅជាដាក់ឈ្មោះញ៉ុម!!

កះហ៊ីម៉េចអ៊ីចឹងវិញ?

ខះ ហ្នឹងសំបុត្រកំនើតហ្នឹងគេធ្វើអោយញ៉ុមខុសតើ!!

កះឡើងខុសឆ្ងាយម៉ងហើយនេះ!!ថ្ងៃខែឆ្នាំកំណើតរបស់ឪរបស់ម៉ែអ៊ីវ៉ាន់ ហា!!ម៉េចអ៊ីចឹងទៅ!!

ខះ សំបុត្រកំណើតហ្នឹងធ្វើខុសតើ!!គេគ្រប់គ្នាក៏ដឹងដែរថាខុសដែរ
ញ៉ុមធ្វើអត្តសញ្ញាណបណ្ណ័គេនិយាយថាខុសអញ្ចឹងដែរហិ!!

កះចាំហើយអ៊ីចឹងម៉េចទៅ?

ខះ ហើយអ៊ីចឹងញ៉ុមមិនដឹងម៉េចដែរ កាលហ្នឹងអ្នកធ្វើនៅភូមិហ្នឹងគេធ្វើអោយហាំ!!

កះហើយអ៊ំអត់ប្រាប់ថ្ងៃខែឆ្នាំកំណើតអោយគេបានគេចេះតែដាក់ៗអ៊ីចឹង?

ខះ
ប្រាប់តើកាលហ្នឹងមានទាំងសៀវភៅគ្រួសារមានទាំងសៀវភៅអីគ្រប់គ្រាន់យកទៅដាក់ហ្នឹង តែអាអ្នកសរសេរហ្នឹងវាសរសេរខុសម៉ងហាំ!!

កះចេះតែមានម៉ងហាំ!!អ៊ីចឹងមិញម្តាយអ៊ំគាត់ឈ្មោះអីគេ?

ខះ កៅជា។

កះ កៅ ជា !!អ៊ំដឹងថាគាត់កើតឆ្នាំខ្មែរគាត់កើតឆ្នាំសត្វអីគេទេអ៊ំ?

ខះ គាត់ឆ្នាំថោះដូចញ៉ុមដែរ គាត់អាយុ៨០ហើយឥឡូវ!!។

កះ ចាំ!!អ៊ំចាំឆ្នាំគាត់កើតទេ?

ខ៖ ញុំមអត់ចាំឆ្នាំគាត់ តែញុំមចាំថាគាត់ឆ្នាំថោះ ហើយឥឡូវអាយុគាត់៨០ហើយ ៨០គត់!!

ក៖ ៨០គត់ហើយហោ?

ខ៖ ចាំ!!

ក៖ អ៊ីចឹងបើអ្នកណាណាចង់ដឹងថ្ងៃខែឆ្នាំកំនើតគាត់ដកតាមហ្នឹងទៅ!!

ខ៖ចាំ!!

ក៖ដោយសារឆ្នាំ២០១៨ ម្ដាយរបស់អ៊ំគាត់អាយុ៨០ឆ្នាំហើយ!!

ខ៖ចាំ!!

ក៖ចាំ!!

ខ៖ ដកតាមហ្នឹងទៅដឹងហើយ!!

ក៖ អ៊ំដឹងថាគាត់អ្នកស្រុកកំណើតកើតជានៅឯណាទេអ៊ំ?

ខ៖ គាត់កើតជានៅភូមិព្រៃកថីហ្នឹងដែរ!!

ក៖ ចាំ!!អញ្ចឹងនៅក្នុងភូមិព្រៃកថី ឃុំរកាខ្ពស់!!

ខ៖ហ្នឹងហើយគាត់កើតនៅម្ដុំហ្នឹង!!

ក៖ នៅស្រុកស្អាង ខេត្តកណ្ដាលហ្នឹងដែរ?

ខ៖ ចាំចាំ!!

ក៖ ចាំអ៊ីចឹងអ៊ំសំរាប់
ម្ដាយរបស់គាត់មានចរិកម៉េចដែរអ៊ំអាចប្រាប់ពីចិត្តគំនិតរបស់គាត់ថាគាត់ជាម្ដាយយ៉ាងម៉េចអ៊ី
ចឹងណាស់!!

ខ៖ តាមការពិត ចិត្តគំនិតម៉ែញុំមនិយាយទៅម៉ែញុំមមនុស្សល្អម៉ង ចូលចិត្តធ្វើបុណ្យ
ឥឡូវគាត់មានលុយកាក់គាត់មានលុយគាត់ច្រើនគាត់មានដីគាត់លក់អ៊ីចឹងណាស់!!

កៈអីយ៉ាស់!!

ខៈ ហើយគាត់មានដីសំរាប់តែដើរធ្វើបុណ្យម៉ង
ហើយជាមួយកូនចៅអីគឺគាត់កំរអោណ្វងអាណាំងម៉េច ចង់អាកូនវាអាម៉េចវាមិនស្តាប់អី
ក៏នៅតែម៉ែញ៉ុមអត់មាត់!!

(មិត្តភក្តិ)ៈ
ណោះកន្លែងគាត់និយាយអោយច្រើនចៅចង់ដឹងណាស់!!អោយដឹងថាយាយគាត់ហ្នឹងល្អៗម៉េច
ៗ។

ខៈ
ហើយនិយាយទៅកូនចៅពិបាកវាធ្វើវាមិនស្តាប់មិនអីវាអាណ្វងអាណាំងវាផឹកវាស៊ីអីកូនៗហ្នឹង
ហាំ!!កៈចាំ!!ខៈម៉ែគាត់អត់ចេះមាត់ចេះករអីទេបង!!ហើយចង់អាកូនប្រសារហ្នឹងនិយាយម៉េច
មាត់ធំមាត់តូចដាក់គាត់ហ្នឹង !!ហើយចែកកេរ្តិ៍អោយកូនមួយកំនរ
អាកូនប្រសារហ្នឹងលេងបៀរនិយាយមិនស្តាប់អីអញ្ចឹងក៏ម៉ែញ៉ុមអត់មាត់ដែរ!!ស្លូត!!
ហ៊ីញ៉ុមថាម៉ែអើយម៉ែម៉ែឯងទាល់តែអញ្ចឹងពេកពិបាកណាស់
កូនប្រសារវាមើលងាយទៀតណាស់! អោយកេរ្តិ៍វាមួយកំនរហើយនិយាយវាអត់ស្តាប់សោះ!!

កៈហ៊ី!!

ខៈ គាត់និយាយទៅដូចថាវាអត់មាន ដូចថាពេលនិយាយទៅគេខឹងដូចថាលែងនិយាយម៉ង!!

(មិត្តភក្តិ)ៈ គាត់មនុស្សល្អម៉ង!!

ខៈ គាត់ធ្វើតែល្អម៉ង!!បើនិយាយទៅខ្លាចនេះថា ខ្លាចកូនខឹងអីអីចឹងណាស់!!

កៈចាំ!!

ខៈនិយាយទៅគាត់មិនចូលចិត្ត មិនចូលចិត្តអញ្ចឹងគាត់អត់និយាយទេ!!

(មិត្តភក្តិ)ៈ គាត់ចង់តែសុខគាត់មិនចង់និយាយ។

ខៈ គាត់គិតតែពីធ្វើបុណ្យធ្វើទានគាត់ទៅ!!

កៈ
ចុះពេលអនុស្សវរីយ៍នៅពេលដែរអ្នកមីងមានជាមួយគាត់ពេលដែលនៅជាមួយគាត់ម៉េចដែរ
ទៅ?គាត់ស្រលាញ់ម៉េចដែរទៅ?

ខៈ គាត់ស្រលាញ់ ស្រលាញ់កូនណាស់!!ស្រលាញ់កូនស្រលាញ់ចៅណាស់
មិនថាទាំងកូនទេចៅទៀត!!អង្គុយមើលចៅមើលអី
តែយើងកូនទូចហើយអាគាត់កូនគាត់ហ្នឹងអាយុជំនាលកូនញ៉ុម
ហើយយើងទៅធ្វើការអញ្ចឹងធ្វើគាត់ណាស់!!

កៈហ្វ៎!!

ខៈម៉ែញ៉ុមមិនថាបានមនុស្សយើង មែន!!មិនមើលយើងត្រឹមយើងទេ
មើលដល់កូនយើងទៀត!!

កៈ ចាំ!!អញ្ចឹងប្អូនអ្នកមីងអាយុជំណាលរបស់កូនអ្នកមីង?

ខៈ ចាំ!!ប្អូនពៅញ៉ុមអាយុជំណាលកូនញ៉ុម។

កៈ តែប្អូនពៅគាត់នៅរស់ដល់សព្វថ្ងៃអ្នកមីងណេះ?

ខៈ ប្អូនពៅ ប្អូនពៅនៅជាមួយគាត់។

កៈ ប្អូនពៅគេអាយុប៉ុន្មានវិញអ្នកមីង?

ខៈ អើរឆ្នាំច ប្រហែលជា៥០ជាងហើយ!!

កៈហ្វ៎ជំណាលបងប្រុសញ៉ុម!!៣០ជាងហ្នឹង ៣៤ ៣៥អីហ្នឹង!!!

ខៈ ជំណាលកូនញ៉ុមមិញហ្នឹង អាប្រុសមិញហ្នឹង!!

កៈចាំ!!

ខៈហ្នឹងប្អូនពៅញ៉ុមជំណាលគ្នា!!កៈហ្វ៎!!ខៈញ៉ុមហើយម៉ែញ៉ុមពោះធំជំណាលគ្នា!!

កះ
មីងដល់ពេលពូហើយក្មួយដំណាលគ្នាអ៊ីចឹងទៅគាត់ហៅពូហៅអីហ្នឹងអ៊ីចឹងដែរទេ?ឬក៏ហៅធម្មតា?

ខះ មុនដំបូងគេហៅឈ្មោះធម្មតាទេ ប៉ុន្តែដល់ពេលប្អូនញ៉ុមគេមានប្ដីមានកូនអ៊ីចឹងទៅអាក្មួយៗហ្នឹងហា!ដែលធ្លាប់ហៅឈ្មោះហ្នឹងហាំហៅមីងអស់ហើយឥឡូវហ្នឹង!!

កះហ្អូដល់ពេលធំៗទៅ!!

ខះ មីពៅញ៉ុម
កាលពេលនៅពីតូចដូចតែគ្នាហៅគ្នាតែអាដូចតែគ្នាហ្នឹង!!ដល់ពេលទៅមានប្ដីមានប្រពន្ធរៀងខ្លួនទៅវាដឹងហាំ!!

កះចាំ!!

ខះដឹងអ៊ីចឹងទៅ គេហៅមីងទៅ ប្រពន្ធណោះគេហៅមីងដែរទៅ!!អាយុប៉ុនៗគ្នាហ្នឹងហាំ!!

កះចាំ
!!អញ្ចឹងអ្នកមីងសំរាប់ម្ដាយរបស់អ្នកមីងតាំងពីដើមមកគាត់រកស៊ីអីគេដែរដើម្បីជួយដល់ក្រុមគ្រួសារអ៊ីចឹងហាំ?

ខះ កាលមុនគាត់ធ្វើចំការហ្នឹង ហើយចិញ្ចឹមគោ ពុកញ៉ុមហ្នឹងគាត់មានគោច្រើនហាំ!!

កះចាំ!!

ខះ គាត់ចិញ្ចឹមគោមេផង ចិញ្ចឹមគោបាផងពុកញ៉ុមហ្នឹង !!ហើយគាត់ច្រើនតែរកស៊ីជួញគោ!!

កះ ទៅជួយគោគាត់អត់មានកាប់គោកាប់អីណាហី?

ខះ អត់ទៅ!!!គាត់ទិញលក់យកចំនេញអីអញ្ចឹងទៅណាស់!!

កះ ហ្អូដូចពុកញ៉ុមឥឡូវដែរហ្នឹងហា!!

ខះ ចាំហ្នឹងគាត់ជួញគោកាលពីដើមពុកញ៉ុមសំបូរគោណាស់
ហើយគាត់ទិញយើងហ្នឹងយកទៅលក់នៅស្រែនៅ អើរកំពង់ស្ពឺកំពង់អីណោះ !!

ក៖ចាំ!!

ខ៖ គាត់ទិញយកពីយើងទៅណាស់ យកទៅលក់ទៅអីយកចំនេញ
ហ្នឹងកាលពីគាត់នៅពីក្មេងនៅមានកំលាំងនៅមានគោគាត់មើលគោធ្វើស្រូវ
ធ្វើចំការអីទៅ!!!ធ្វើអីធម្មតាអិចឹងទៅណាស់!!

ក៖ មុនសង្គ្រាមឬក៏អី?

ខ៖ ចាំកាលហ្នឹងមុនសង្គ្រាមអី ក៏គាត់រកស៊ីមុខរបរហ្នឹងដែរ!!

ក៖ គោប៉ុន្មានទៅមីងនៅផ្ទះអីវ៉ាន់?

ខ៖ បើញ៉ុមធ្លាប់ឃើញគោច្រើនណាស់និយាយទៅ គាត់ធ្វើមុងដាក់ក្រោមផ្ទះ
និយាយទៅផ្ទះគាត់ប៉ុនផ្ទះញ៉ុមអ៊ីចឹង
ហើយគាត់ធ្វើមុងដាក់ពេញឡើងមួយក្រោមផ្ទះអិចឹងចងគោខាងហ្នឹងពេញម៉ង មានអាគោបា
មានអាគោមេ មានអាស្ទាវអីឡើងទាំងរ៉ូង ប្រលែង ប្រលែងយកនេះស៊ី
ប្រលែងអោយស៊ីតាមទួលប្រសាទតាមទួលអី !!

(មិត្តភក្តិ)៖ ពីដើមស្មៅស្រួលណាស់!!

ខ៖ ទួលក្រសាំងហ្នឹងហាំ!!

ក៖ចាំ!!

ខ៖ ស្មៅកាលហ្នឹងសំបូរណាស់!!

ក៖ មិនមែនពិបាកដូចឥឡូវ!!

ខ៖ មិនមែនដូចឥឡូវទេ!!

ក៖ ឥឡូវអីៗប្រែប្រួលច្រើនណាស់!!

ខ៖ ឥឡូវអីៗប្រែប្រួលច្រើនណាស់យើងឥលូវហ្នឹងដឹកគោតាមផ្លូវហ្នឹងអត់ដឹងផង
ឡានច្រើនម៉ូតូច្រើនអ៊ីចឹងណាស់!!

កៈចា៎!!

ខៈហើយយើងលើកមុនណាផ្លូវប្រហែលគោទាំងរ៉ូងហ្នឹង ឥឡូវអត់មាន អត់មានស្រួល!!

(មិត្តភក្តិ)ៈ ចាស់ៗពីដើមមិនបាច់ទាំងឃ្វាលផង លែងអីចឹងល្ងាចវាដើរមក!!

ខៈ លែងហ្នឹង!! ហ្នឹងហើយ!!

កៈ គោវាដឹងម៉ងអ្នកមីង?

ខៈ វាដឹង!!

កៈ ហើយអ្នកមីងភាគច្រើនម៉ែគាត់ធ្វើស្រូវដែរហោ?

ខៈ គាត់ធ្វើស្រូវ ខែធ្វើស្រូវគាត់ធ្វើស្រូវអីចឹងទៅ
គាត់យកមកដាក់ជង្រុកទុកហូបទៅណាស់!!កៈចា៎!!

ខៈហើយក្រៅពីហ្នឹងគាត់ដាំចំការ ដាំដូចញ៉ុមនិយាយអីចឹង ជួនកាលគាត់ដាំត្រប់
ជួនកាលគាត់ដាំត្រសក់ ដាំម្រះ អីអិចឹងទៅ ផុតពីធ្វើស្រូវហា៎!!

កៈចា៎!!

ខៈ ហើយពុកញ៉ុមគាត់មើលគាត់មើលអីទៅ ហើយពេល ពេលគាត់មកពីកំពង់ស្ពឺ
គេពឹងអោយគាត់ដើរជួយទិញគោហា៎ គាត់ស្គាល់គោ គាត់ស្គាល់ក្របៅ
ស្គាល់អីម៉េចអីចឹងគាត់ចេះហា៎!! ហើយអញ្ចឹងគេមកពីឆ្ងាយៗគេពឹងអោយគាត់ដើរជួយទិញ
ហើយអោយជួយទិញអីចឹងទៅគាត់បានចំនេញទៅណាស់!!ជួយទិញគេបានគេអោយលុយ
អោយអីអីចឹងទៅ!! គាត់ចិញ្ចឹមកូនដូចស្រួលដែរកាលហ្នឹង។

កៈ ហោធូរដែរ រកស៊ីធូរ!!

ខៈ អត់ពិបាកទេ!!នៅជាមួយម៉ែពុក អត់សូវដែលថាខ្វះហូបចុកទេបងណាស់!!
ញ៉ុមអត់ដែលចេះខ្វល់ទេ!!!

កៈ អត់សូវ និយាយទៅបើសិនជាមិនសង្គ្រាមហ្នឹងស្រួលម៉ងអ្នកមីង!!

ខ៖ ហ្នឹងបើសិនជាកុំសង្គ្រាមហ្នឹងវិញ ដូចថាជីវភាពកំពុងតែជឿនទ្បើនហើយ ដល់ពេលស្រុកកំពង់តែសង្គ្រាមទៅ គោទាំងរ៉ូងគេប្រមូលចូលក្នុងអង្គភាពអស់រលីង!!

(មិត្តភក្តិ)៖ អីចឹងតើ!!

ខ៖ ចាំមានទាំងគោទឹមមានទាំងមេមានទាំងអីទាំងអស់!!បងអើយគេប្រមូលចូលរួមទាំងអស់!!

(មិត្តភក្តិ)៖ ប្រមូលចូលសមូហភាពអស់ទៅ!!

ខ៖
ចាំប្រមូលចូលសមូហភាពអស់ទៅ!!ដល់ពេលបែកអាពតហើយអិចឹងទៅគោយើងប្រហែលអាសេកអាសាច!!

ក៖ ពេញតាមផ្លូវអីចឹងទៅ?

ខ៖ ពេញតាមអីចឹងទៅគាត់ចាប់បានមេមួយចិញ្ចឹមទៀតទៅ!! ចិញ្ចឹមទៅបានកូនបានចៅបែកចែកកូនចែកចៅ ចែកញ៉ុមចែកអីគ្រប់គ្នាចិញ្ចឹមលាន់រហូតអីចឹងទៀតមក!!

ក៖ ចាំ ស្រុកខ្មែរយើងណាស់អ៊ំ
ទាំងគ្រួសារយើងគ្រួសារអ៊ំគ្រប់គ្នាទាំងអស់មកហ្នឹងហាំបើសិនជានេះហាំ!!បើសិនជាកុំសង្គ្រាមមិនដឹងប្រទេសយើងរីកចំរើនដល់ថ្នាក់ណាទេអ៊ំអើយ!!ខ៖ចាំ!!ក៖ មួយៗមានងាប់អស់ហើយ!!

ខ៖ ហ្នឹងហើយ!!

ក៖ និយាយទៅដូចថាដើរខុសមួយជើងដើរខុសដល់ករម៉ងហើយណាស់!!

ខ៖ រលាយនគរម៉ងហ្នឹង!!

ក៖ចាំ!!

ខ៖ អាមនុស្សក៏ងាប់ជិតអស់ អាទ្រព្យសម្បត្តិក៏រលាយហិនហោច
អាផ្ទះក៏រត់ចោលគេជំលៀសទៅក្រោមហ្នូ!! ផ្ទះប៉ុនៗណាណីមិនទុកចោល!!

(មិត្តភក្តិ)៖ រ៉ូសចោលមិនយកធ្វើស្អីៗ!!

ក៖ ដុតចោល។

ខ៖ ជួនកាលបាញ់ទៅឆេះចោលអត់ដឹងអី!!

(មិត្តភក្តិ)៖ និយាយទៅបំផ្លាញម៉ង!!

ខ៖ បំផ្លាញម៉ង!! សង្គ្រាមបំផ្លាញខ្លួនម៉ងហ្នឹងហា៎!!

ក៖ មិនដឹងគិតឃើញម៉េចទេអ៊ំបាននាំគ្នាគិតឃើញឆ្កួតទាំងអស់គ្នាអ៊ីចឹងទៅនេះហ៎! ដូចជាការគិតរបស់តែមនុស្សមួយក្រុមតូចសោះនាំអោយគេវេទនាមួយប្រទេសហា៎!! ហ៊ីយ៉ាប់ណាស់ ហើយអ៊ីចឹងអ៊ំ អ៊ំមានអីទៀតដែលចង់និយាយប្រាប់ពីគាត់ ដែលចង់ទុកអោយកូនចៅស្តាប់អ៊ីចឹងណាស់!!

ខ៖
គ្រាន់តែចាំបានថានៅជាមួយគាត់កក់ក្តៅម៉ងហា៎!គាត់មិនដែលអោយកូនពិបាកម៉ងហា៎!!ក៖ចា៎!!ខ៖មានហូបមានចុកគ្រប់គ្រាន់សំរាប់យើង!!

ក៖
ចា៎អ៊ីចឹងអ៊ំពេលគាត់ដាំបន្លែដំាអីអញ្ចឹងមកដូចរបៀបថាមានគេយកលក់ទៅផ្សារឬក៏គេមានមកទិញដល់ផ្ទះ?

ខ៖ជួនកាលមានម៉ូយទិញដល់ផ្ទះជួនកាលអ៊ីចឹងទៅមានញ៉ុមអីហ្នឹងមានយកលក់អោយគាត់នៅផ្សារអ៊ីចឹងទៅ!!

ក៖ ផ្សារនៅកន្លែងណាវិញ?

ខ៖ ផ្សារនៅតាខ្មៅ។

ក៖ ផ្សារតាខ្មៅណោះ?

ខ៖ចា៎!!ផ្សារតាខ្មៅ!!

ក៖ អ៊ីចឹងពេលមុនអាផ្សារនៅជិតវត្តឈ្លូងលៀបហ្នឹងមានទេអ៊ំ?

ខ៖ បើស្រុកយើងកាលនៅសង្គ្រាមនោះផ្សារ
ឈូងលៀបយើងក៏មានផ្សារដែរពីមុនហើយដល់ឥឡូវក៏មានផ្សារនៅវត្តឈូងលៀបហ្នឹងដែរកាលពីយើងសង្គមចាស់នោះណាស់!!ក៖ហ៊ីៗ!!ខ៖កាលពេលនៅសង្គ្រាមហ្នឹងក៏មានផ្សារនៅហ្នឹងដែរ!!

ក៖ចា៎!!

ខ៖អ៊ិចឹងពេលណាយើងបានតិចអ៊ីចឹងទៅយើងលក់ជិតផ្ទះពេលណាច្រើនដឹកទាំងរទេះទាំងរម៉ក់ណោះមិនយកទៅលក់នៅផ្សារលើ !!

ក៖ចា៎!!

ខ៖ចា៎!!

ក៖ បានថ្លៃទេអ៊ំនៅជំនាន់ហ្នឹង?

ខ៖បានថ្លៃហ្នឹង ប៉ុន្តែលុយនិយាយទៅលក់បានលុយតិចក៏វាថ្លៃអីតាមហ្នឹងដែរ
ព្រោះយើងទិញអស់ថ្លៃបន្តិចដែរ!!

ក៖ចា៎!!និយាយទៅអ្វីៗទាំងអស់វាស្របទៅតាមសង្គមអ៊ីចឹងណាស់អ៊ំ!!

ខ៖ចា៎!!

ក៖ចា៎!អ៊ិចឹងអ៊ំសំរាប់ឪពុកវិញឪពុកគាត់ឈ្មោះអីគេដែរ?

ខ៖ ម៉ី យ៉ាន់។

ក៖ ម៉ី យ៉ាន់?

ខ៖ចា៎!!

ក៖ហើយចុះម៉េចឈ្មោះអ្នកណាគេនេះហាំឈ្មោះថុល កុសល្យនៅក្នុងសំបុត្រកំនើតវិញ?

ខ៖ ថុល កុសល្យ ប្តី!!

កៈ
នេះគេដាក់ហាំអញ្ចេះនិយាយទៅយកឈ្មោះនៅក្នុងសំបុត្រកំនើតយកឈ្មោះប្តីហើយនឹងអ៊ំមកដាក់ទៅនេះ!!

ខៈ អ៊ីចឹងបានថាមិនដឹងគេសរសេរអោយម៉េច?

កៈ ហ៊ីយ៉ាប់តែម្តង អត់មានទៀតហាំអាអ្នកសរសេរអោយនេះហិ!!

ខៈ យកប្តីញ៉ុមមកធ្វើឪពុក !!

កៈចាំ!!

ខៈ យកខ្ញុំធ្វើម្តាយ!!

កៈ វាអត់កើតសោះតែម្តងណាស់!!

ខៈ ចាំ!!អ្នកសរសេរហ្នឹងសរសេរខុសតែម្តងហ្នឹងហាំ!!

កៈចាំ!!អ៊ិចឹងអ៊ំសំរាប់ឪពុករបស់អ៊ំគាត់កើត ហាគាត់នៅមានជីវិតដល់សព្វថ្ងៃ?

ខៈ អត់ទេ!!ស្លាប់ហើយ!!។

កៈ គាត់ស្លាប់នៅឆ្នាំណាវិញអ៊ំ?

ខៈ គាត់ស្លាប់នៅឆ្នាំ២០១២។

កៈ ហ្ហ៎ទឹមដែរហ្នឹងហោំ!!

ខៈចា!!

កៈរួចពីសង្គ្រាមដែរ!!ពេលគាត់ស្លាប់អាយុប៉ុន្មានអ៊ំចាំទេ?

ខៈតាមគាត់ស្លាប់៧៩(១៩៧៩)។

កៈអាយុ៧៩ឆ្នាំ?

ខៈចាំ!!

កះអញ្ចឹងដកគុណចែកអីទៅគេដឹងថាគាត់កើតឆ្នាំពេលណាហើយ!!

ខះចាំ!!

កះសំរាប់ឆ្នាំខ្មែរឪពុគាត់កើតឆ្នាំអីគេអ៊ំ?

ខះ ច!!

កះច ហោ!!អញ្ចឹងបងរបស់យាយដែរ! ប្តី!!

ខះ បងរបស់ម៉ែញុំម!!

កះបងតែប៉ុន្មានឆ្នាំហ្នឹង!!!

ខះ ៥!!!

កះ
ចាំ!!អីចឹងអ៊ំសំរាប់ឪពុករបស់អ៊ំគាត់ជាមនុស្សយ៉ាងម៉េចដែរអ៊ំនិយាយប្រាប់ពីឪពុកវិញម្តង!!មិញម្តាយហើយហើយ!!

ខះ គាត់និយាយទៅឪពុកញុំមគាត់ល្អ!! គ្រាន់គាត់មានដែលមានស្រីមានញីអីទេ
ឃើញពុកមានដែលមានស្រីមានអីមានញីអីទេ!

កះចាំ!!

ខះគាត់ចិញ្ចឹមកូនចៅ គាត់រកស៊ីចិញ្ចឹមកូនចៅ គាត់ពូកែធ្វើស្រូវធ្វើអង្ករណាស់!!ពុកញុំម!!

កះចាំ!!

ខះធ្វើចំការហ្នឹងគាត់ប៉ុនណាស់!!ហើយដៃគាត់ត្រជាក់ណាស់ ដាំអីក៏បានដែរ
ម៉ែញុំមនៅសរសើរគាត់ដល់រាល់ថ្ងៃ!!

កះចាំ!!

ខះថាពុកឯ៉ងអោយតែគាត់ដាំអីដាក់ដល់ដីដឹងតែល្អម៉ង !!

កៈ អីគេដែរអ៊ំដែលផ្លែមកបានល្អៗច្រើនៗហ្នឹង?ទាំងមានអីគេខ្លះ?

ខៈ និយាយរួមមានទាំងគាត់ដាំពោតដែរ!!ដាំពោតដាំត្រសក់ដាំត្រលាច អោយតែពុកជួយដំាដឹងតែដុះល្អហើយផ្លែល្អម៉ង!!

កៈ ហ្នឹងហើយ!!

ខៈ ម៉េញ៉ុមតែងតែសរសើររហូតគាត់នៅតែថាពុកង៉ែងដៃគាត់ត្រជាក់ណាស់!!!ដាំអីក៏បានដែរ!!

កៈ ចាំនិយាយរួមទៅជំនឿរបស់ខ្មែរយើងភាគច្រើនតែអញ្ចឹងម៉ង!!

ខៈចាំ!!

កៈតែមែនតើអ៊ំ!!

ខៈហ្នឹងហើយ!!

កៈ អ្នកណាគេត្រូវដាំអីបានដាំបានណាស់!!

ខៈចាំ!!

កៈតែបើអ្នកខ្លះវិញអត់គឺយ៉ាប់ម៉ង!!អ៊ំមានអីចាំពីគាត់ទៀតទេ?ដូចមើលគាត់រកស៊ីជួញគោមើលក្រៅពីរកស៊ីជួញគោមើលអ៊ំគាត់មានរកអីទៀតទេអ៊ំ?

ខៈ ដាំជំនាំដូចញ៉ុមនិយាយអ៊ីចឹង!!កៈចាំ!!ខៈដាំត្រលាច ត្រសក់អី ពោត សណ្តែកអី អ៊ីចឹងទៅណាស់!!កៈចាំ!!ខៈហ្នឹង!!

កៈតែប៉ុណ្ណឹងទេ!!

ខៈ ធ្វើស្រូវធ្វើអីអញ្ចឹងទៅ!!

កៈ ចាំ!!

ខៈមិនដែលទិញអង្ករទេ គាត់ធ្វើស្រូវដាក់ជង្រុកទុកអោយកូនហូប!!

កៈហ៊ឺៗ!!

ខ៖ អត់ចេះខ្វះទេ!!

ក៖ពេញៗជង្រុកម៉ងអ៊ំណោះ?

ខ៖ ចា៎!!អត់ដែលចេះខ្វះអង្ករហូបទេ!!

ក៖មិនមែនធ្វើស្រូវនៅក្រោយនេះណាអ៊ំហេ!!ហ៊ីនៅព្រៃកថីនេះ?

ខ៖ ធ្វើញ៉ុមកាលពីមុន
និយាយពីយើងត្រឹមបែកអាពតហើយគេចែកដីអោយញ៉ុមនោះគេហៅបែកចាន ផ្គរលាន់ !!

ក៖ ផ្គរលាន់ហេ!!

ខ៖ ចា៎ គេហៅទៅខាងណោះ
ឥឡូវដីផ្ទះហ្នឹងគេទិញយកអស់ហើយៗក៖ចា៎!!ខ៖កាលជំនាន់ហ្នឹងយើងធ្វើស្រូវកាលជំនាន់ហ្នឹងយើងទឹមតែបែកអាពតហើយហា៎!!!ក៖ចា៎!!ខ៖ចែកដីអោយធ្វើស្រូវ
ហើយបើពីសង្គមចាស់វិញធ្វើនៅទួលប្រាសាទនេះ។

ក៖ ទួលប្រាសាទនៅណាវិញអ៊ំ?

ខ៖ នេះទួលប្រាសាទនៅអាយើងជិះមកហ្នឹង!!

ក៖ គេហៅទួលប្រាសាទហ្នឹងហេ?

ខ៖ចា៎!!ទួលក្រសាំង ខាងកើតទួលក្រសាំងតិចហ្នឹង គេហៅទួលប្រាសាទ !!

ក៖ចា៎!!

ខ៖ យើងមានដីនៅហ្នឹងកាលពីសង្គមចាស់ហា៎!!ឪពុកញ៉ុមធ្វើស្រូវនៅហ្នឹង!!

ក៖ អត់មានអត់មានអើរនេសាទអីទេអ៊ំ ដោយសារផ្ទះអ៊ំនៅជិតទន្លេអ៊ីចឹងណាស់?

ខ៖ អត់ អត់ចេះពុកអត់ចេះនេសាទេ!!

ក៖ អ៊ីចឹងទិញត្រីទិញអីទៅផ្សារអ៊ីចឹងទៅ!!

ខ៖ ទៅផ្សារអ៊ីចឹងទៅ ជូនកាលគាត់ពាក់មងពាក់អីដែរហ្នឹង!!

ក៖ហ្នូ៎!!

ខ៖ឃើញគាត់ធ្លាប់ពាក់មងពាក់អី តែគាត់គ្រាន់តែពាក់គ្រាន់តែហូបទេណាស់ ពាក់២ដៃគ្រាន់តែហូបទេ អត់មានពាក់លក់ទេ!!

ក៖ចាំហ្នឹងហើយ និយាយទៅញ៉ុមជិះមកមិញតាមផ្លូវណាស់អ៊ំ ញ៉ុមឃើញច្រាំងបាក់ហាំ!!គេ គេនៅនេះគេអត់មានទប់ស្កាត់អីទេអ៊ំហេ?

ខ៖ អត់ អត់ដឹងទប់ម៉េច!!

ក៖វាបាក់មកហើយ!!

ខ៖ បាក់មក!!

ក៖ តែបើអញ្ចេក បើ!! អាហ្នឹងវាបញ្ហាហើយអ៊ំ វាបញ្ហាផ្លូវហ្នូ៎!!

ខ៖ចាំ!!

ក៖អញ្ចឹងបើវាបាក់មក យើងអត់រកវិធានការអីយកមកទប់ស្កាត់អីទេ ប្រជាជននៅហ្នឹងក៏អត់មានមាត់អីគេដែរ?អត់មានឮអីណាអ៊ំណេះ?

ខ៖ ហ៊ឺអាកន្លែងបាក់ហ្នឹងគេអោយមកនៅក្រោយ គេអោយដីតើ!!

ក៖ហ្នូ៎!!

ខ៖រដ្ឋហាំ!

ក៖ចាំ!

ខ៖ គេដោះស្រាយអោយពីអារឿងបាក់ហ្នឹងហាំ!! អ្នកមីងនៅក្រោយៗហ្នឹងផ្ទះបាក់អស់ហើយវាប៉ុន្មាន វា៩គ្រួសារហាំ!!

ក៖ចាំ!!តែពេលមុនមកអាកន្លែងផ្លូវហ្នឹងវាមានដែរអ៊ំហេ? ពីដើមមកផ្លូវជិះមកហ្នឹងហ្នូ៎!!

ខ៖ អត់មានផ្ទះហ្អែងមើល!!

ក៖ ដូចរបៀបថាមានផ្លូវមានអីអញ្ជឹងតាំងពីដើមមកឬក៏យ៉ាងម៉េច?

ខ៖ចាំ!!ផ្លូវហ្នឹងមានតាំងពីដើមមក !!

ក៖ហ្ហ៎!!

ខ៖ផ្លូវយើងនេះក៏មានតាំងពីដើមមកគ្រាន់តែថាផ្លូវរទេះហាំ!!

ក៖ចាំ!!

ខ៖ដើរធម្មតា ដល់ឥឡូវគេចាក់!!

ក៖ គេចាក់បេតុងចាក់អីអោយអ៊ីចឹងទៅ!!
ហ្នឹងញ៉ុមពេលជិះមកអីវ៉ាន់ញ៉ុមឃើញច្រាំងបាក់ហើយឃើញគេបូមខ្សាច់អីវ៉ាន់នៅហ្នឹងច្រើនណាស់!!

ខ៖ គេបូមខ្សាច់ច្រើន។

ក៖ ដល់ពេលបូមអ៊ីចឹងទៅថីអ៊ីចឹងបានច្រាំងបាក់អញ្ជឹងអំណាស់!!

ខ៖ហ្នឹង ប៉ុន្តែយើងនិយាយធ្វើអីបើច្បាប់គេស្តារទន្លេទៅហើយ!!

ក៖ ហ្នឹងហើយ គេអោយនេះហើយ!!

ខ៖ គេអោយស្តារទន្លេទៅហើយ!!

ក៖ ស្តារទន្លេទៀត?

ខ៖ ស្តារទន្លេហាំ!!

ក៖ ហើយទៅស្តារវិញដើម្បីអោយវាជ្រៅ?

ខ៖ ស្តារអោយវាជ្រៅហើយដើម្បីអោយគេបូមខ្សាច់ហ្នឹងយកទៅដាក់កន្លែងហ្នឹងនោះទូលក្រសាំងទូលប្រាសាទហ្នឹង!!

កៈហ្ន៎!!

ខៈ មកហ្នឹងឃើញទេ ឃើញគេបូមខ្សាច់ហ្នឹងពេញហ្នឹងហើយហើយឥឡូវ!!

កៈហ្ន៎អញ្ចឹងបូមពីហ្នឹងទៅដាក់ណោះទេអីចឹង?

ខៈហ្នឹងហើយបូមពីទន្លេទៅ!!

កៈ គោលបំណងធ្វើអីគេវិញអ៊ំ?

ខៈ គេធ្វើ ធ្វើ!!

កៈ ដឹងតែស្ពានទន្លេហើយ ប៉ុន្តែនៅណោះគេធ្វើផ្ទះល្វែងធ្វើអីអញ្ចឹងទៅអ៊ំណេះ?

ខៈ ហ្នឹងហើយ គេធ្វើផ្ទះល្វែងធ្វើអីអញ្ចឹងៗទៅ!!ទិញដីនៅហ្នឹង បូមខ្សាច់ពីហ្នឹងទៅ!!

កៈចា៎!!អីចឹង តែពេលមុនវាអត់មានបាក់អីអញ្ចឹងទៅ តែពីដើមមកវារាងឆ្ងាយដែរអ៊ំហេ?

ខៈ វាទន្លេវាតែងតែបាក់ហើយ តែគ្រាន់តែថាវាបាក់សន្សឹមៗ!!

កៈចា៎!!

ខៈពេលភ្លៀង ហាពេលទឹកឡើងអីអញ្ចឹងទៅវាបាក់ដែរ បាក់តិចៗហា៎!!

កៈហ៊ឺៗ!!ខៈ ទឹមតែឥឡូវគេទឹមស្ពានទន្លេហ្នឹងវារឹងតែបាក់ខ្លាំងម៉ងហា៎ បាក់ខ្លាំង!!

កៈ
ខ្លាំងម៉ងហា៎!!អ៊ំមានចាំអីគេទៀតពីឪពុកទេ?ដូចគាត់មានដែលនាំគ្រួសារឬក៏កូនអីដើរលេងអីអត់ទេអ៊ំ?

ខៈ និយាយទៅអត់ដែលបានដើរលេងដោយសារពួកញ៉ុមធំឡើងនៅក្នុងសម័យប៉ុល ពត !!

កៈហ៊ឺ!!

ខ៖ហើយមិនដឹងទៅលេងឯណាទេមានតែធ្វើរ
មានតែថាមិនទាន់គេចូលរួមមិនទាន់គេប្រមូលគោហ្នឹង ចេះតែមើលគោធ្វើចំការជាមួយក្រុម
ក្រុមកាលហ្នឹងគេហៅក្រុមសាមគ្គី!!

ក៖ចាំ!!

ខ៖ធ្វើអីតាមក្រុមអញ្ចឹងទៅណាស់!!ដាំពោតអីចឹងតាមក្រុមអញ្ចឹងពេលកាច់ទៅចែកគ្នាអីចឹង
ទៅណាស់ !!

ក៖ហ្ហ៎!!

ខ៖កាលហ្នឹងនៅក្នុងជំនាន់អាពតយើងអត់ទាន់បែកឆ្នាំ៧៥(១៩៧៥)ហាំ!!

ក៖ចាំ!!

ខ៖យើងធ្វើអីធ្វើនៅក្នុងក្រុមសាមគ្គីហ្នឹង!!ក៖ចាំ!!ខ៖ ហើយអញ្ចឹងមានពេលណាដើរលេង!!

ក៖ អត់មានម៉ង!!

ខ៖ ដូចអត់មានម៉ង!!

ក៖ ដូចនៅពីដូចនៅពីក្មេងៗអីពុកអត់នាំទៅណាដែរអ៊ំ?

ខ៖ ដូចអត់ដែលនាំទៅណាទេ!!

ក៖ចាំ!!

ខ៖ អត់ដែលនាំទៅឆ្ងាយផងព្រោះអីពុកញ៉ុមមិនសូវជាអ្នកដើរ
គាត់អ្នកចំការអីចឹងដូចថាធ្វើតែចំការ មើលគោមើលពពែគាត់
មើលគាត់ទៅណាគាត់ទៅទិញគោទៅតែគាត់ទៅ គាត់ទៅលក់គោគាត់ទៅតែគាត់!!

ក៖ ចាំ!!អត់ដូច អត់ដូចសម័យឥលូវចូលចិត្តដើរលេង!!

ខ៖ហ្នឹងហើយចូលចិត្ត!!

ក៖ ដល់ពេលសុម័យមុនចូលចិត្តនៅផ្ទះ!!

ខះហ្នឹង !! បើសិនជាសម័យមុនអត់ អត់ដែលបានដើរលេងអីទេ!!

កះ តែសប្បាយ ស្រុកសុខសប្បាយ!!

ខះ សប្បាយ!!

កះ ចាំអញ្ចឹងអំសំរាប់ចូលដល់ជីដូនជីតាខាងម្ដាយវិញ យាយគាត់ឈ្មោះអីគេដែរ?

ខះ យាយឈ្មោះផុន?

កះចាំត្រកូលគាត់អត់?

ខះ អត់ចាំ!!

កះ អត់ចាំ!អំកើតទាន់គាត់ទេ?

ខះ ទាន់!!

កះ យាយស្លាប់ពេលណាវិញ?

ខះ យាយស្លាប់ មិនដឹងអត់ចាំស្លាប់ទេនេះ ស្លាប់យូរដែរហើយ!!

កះ ហ៊ឺៗ!!ពេលបែកសង្គ្រាមឬក៏មុនសង្គ្រាមអំ?

ខះបែក!!

កះបែកហើយ!!

ខះ បែកហើយហើយ ញ៉ុមកើតកូនបងហាញ៉ុមកើតកូនទីពីរហើយបានគាត់ស្លាប់ហ្នំ!!

កះហើយឥឡូវកូនទីពីរអាយុប៉ុន្មានហើយ?

ខះ កូនទីពីរឆ្នាំខាល!!

កះឆ្នាំខាល អ៊ីចឹងអោយគាត់គិតគួរមើលតាមហ្នឹងទៅ!!ឆ្នាំខាលតែអាយុប៉ុន្មានអំ?អត់នេះ ៣០ប៉ុន្មាន?

ខ៖ ៣០ហើយ!!

ក៖ ៣២អីវ៉ាន់ហ្នឹង!!

ខ៖ហ៊ុ!!

ក៖ហើយអ៊ំយាយគាត់ស្លាប់មូលហេតុអីគេដែរ?

ខ៖ គាត់ចាស់!!

ក៖ ចុះប៉ាមិញគាត់ស្លាប់មូលហេតុអីគេ ចាស់ដែរហើអី?

ខ៖ ហ្នឹងហើយ សុទ្ធតែជំងឺគាត់ចាស់ដែរហើយ៧៩ហើយ!!

ក៖ហ្នឹងហើយគាត់៧៩ហើយហ្ន៎!!

ខ៖ គាត់៧៩!!

ក៖ចាំ!!

ខ៖ហើយយាយ យាយចាស់ដែរហើយប៉ុនញ៉ុមអត់ដឹងអាយុប៉ុន្មានទេកាលហ្នឹង!!

ក៖ អ៊ំចាំឆ្នាំខ្មែរយាយទេ?

ខ៖ អត់!!

ក៖អត់ទេហេ?ចាំ!!អញ្ចឹងអ៊ំសំរាប់នេះហា!!　ហើយអ៊ំពេលណាបានត្រូវកាត់ថ្មី?

ខ៖ អើរសុទ្ធតែកាត់រាល់តែថ្ងៃតើ ទឹមតែថ្ងៃហ្នឹងអត់កាត់ទេ ខំធ្វើស្មៅ
ស្មៅវាច្រើនពេកហាំ!ស្មៅវាលុបពេក !!ញ៉ុមសុទ្ធតែកាត់រាល់ថ្ងៃហ្នឹង
កាត់ម្នាក់ឯងបានតែ៣០គីឡូរអីវ៉ាន់ហ្នឹង!!

ក៖ ១គីឡូបានប៉ុន្មានដែរអ៊ំថ្មី?

ខ៖បានតែ១០០០ហ្នឹងឥឡូវ!!

ក៖ហ៊ុអញ្ចឹងមួយថ្ងៃៗអ៊ំរៀងបានចូលចំនូលច្រើនដែរហ្នឹង!!

ខ៖ ចូលបាន២០០០០ ៣០០០០អីហ្នឹង!!

ក៖ ហ៊ឺអញ្ចឹងល្អហើយអឺចឹងមានមុនរបរនៅផ្ទះ!!

ខ៖ មានតើ!!

ក៖ចា៎!!

ខ៖អត់ អត់ទេ ២០០០០ ៣០០០០ អីហ្នឹង!!

ក៖ ចា៎អញ្ចឹងអ៊ំមានចាំអីពីយាយទៀតទេ?មើលអនុស្សាវរីយ៍ពីយាយ?

ខ៖ ហ្អ៎បើអនុស្សាវរីយ៍ពីយាយវិញហា៎ រឹតតែល្អសឹងចង់ជាងម៉ែទៀត!!

ក៖អូយ!!

ខ៖យាយនៅធ្លាប់តែម៉ែញ៉ុមគាត់កូនច្រើនអ៊ិចឹងគាត់យកញ៉ុមទៅនៅជាមួយហា៎!!

(មិត្តភក្តិ)៖ សុទ្ធតែមនុស្សសុចរិត!!

ក៖ ចា៎យាយញ៉ុមក៏គាត់ពូកែគាត់ធ្វើបុណ្យធ្វើទាន ធ្វើបុណ្យទានហ្នឹងម្ហូបអាហារប្រគេនលោកអីអញ្ចឹងណាស់!!គាត់ចូលចិត្តម៉ង!!គាត់ចេះធម៌ទៀត!!

(មិត្តភក្តិ)៖ គាត់ធ្វើបុណ្យគាត់អត់ដឹង ធូរឯងខំប្រឹងធ្វើម៉េចអោយបានទៅព្រះវិហារបរិសុទ្ធយកឈ្មោះគាត់!!

ខ៖ ចង់ទៅតើ!ញ៉ុមទៅផ្ញើរម៉ាន់ សំខាន់អោយតែខ្លួនយើងល្អសិនទៅលុយកាក់អត់ខ្វះទេ!!

(មិត្តភក្តិ)៖ អញ្ចឹងបានថាស្រួលនេះ!!

ខ៖ លុយកាក់មិនអត់ទៅទេ!!ក៖ចា៎!!ខ៖ សំខាន់ខ្លួនយើងអត់ទាន់សាកសមអឺចឹងណាស់!!

ក៖ម៉េចបានគិតថាខ្លួនឯងមិនសាកសម?

ខ៖ ចុះបើ មិនទាន់សាកសមបើយើងដូចថាយើងបងឯងមើល មើលអក្សរគេមើលមិនរួច ឥលូវហ្នឹងមើលភ្នែកញ៉ុមវារឹតតែខ្វាក់ចំម៉ងមិនមែន!!ហើយសំខាន់ថាអោយវាបានទៅព្រះវិហារបានជាប់ជូនទៅណាស់!!

(មិត្តភក្តិ)៖ និយាយទៅទាល់តែយើងសាកសម!!

ខ៖ចាំ!!

ក៖ និយាយទៅអត់អីទេអ៊ំ!!

ខ៖ បង់ដង្វាយទៀងទាត់ញ៉ុមខំប្រឹងប៉ុណ្ណឹងហើយ ញ៉ុមខំរឿងដង្វាយ!!

ក៖ ហ្នឹងប៉ុណ្ណឹងហើយ!!រកប៉ុន្មានទៀត!!

ខ៖ ហើយញ៉ុមខំធ្វើចិត្តហ្នឹងទៅព្រះវិហារ ខានតែមួយអាទិត្យហ្នឹងស្តាយអើយស្តាយស្តាយរឿង!!

(មិត្តភក្តិ)៖ ខំធ្វើចិត្តហើយថ្ងៃអាទិត្យខំសូវ បញ្ញត្តិព្រះអង្គយើងកុំសូវចាយលុយកុំលក់កុំទិញថ្ងៃអាទិត្យហ្នឹងគោរពអាហ្នឹងអោយបានទៀតល្អណាស់!!

ក៖ អ៊ំជិត១០០%ហើយហ្នឹង និយាយទៅមិនចាំបាច់ល្អឥតខ្ចោះទេអ៊ំ
មិនដែលមានអ្នកណាល្អឥតខ្ចោះទេ!!

(មិត្តភក្តិ)៖ ព្រោះយើងមនុស្សនៅលើផែនដីវាមានបាបហាំ!!

ក៖ ព្យាយាមម៉េចដើម្បីធ្វើចិត្ត!!

ខ៖ ហើយបងឯងមើលហើយបើទៅហើយតែម្នាក់ឯងទៀត!!

ក៖ ទៅសិនទៅអ៊ំអើយកុំចាំគ្នា!!

(មិត្តភក្តិ)៖យើងទៅខ្លួនយើងសិន យើងទៅជួយជូនតាសិន!!

ខ៖ ចាំគេឯណាបើគេណា បើយើងអង្គុយចាំគេ!!

ក៖ចាំ!!

ខ៖ អត់ចាំទេអត់មានចាំអ្នកណាគេទេ!!ចង់ថាតែត្រូវតែទៅទៅហើយ!!

(មិត្តភក្តិ)៖ បងប្អូនកូនចៅអត់ស្គាល់ យើងទៅហ្នឹងមួយហ្នឹងដើម្បីយើងជួយពួកគេ!!

ក៖ អ៊ំចូលរៀនថ្នាក់ជាមួយម៉ែជាមួយអីទៅដំណាលគ្នាទៅ!!

ខ៖ បងបងឯងទៅអង្កាល់ហើយ?

ក៖ជិតហើយ!!

(មិត្តភក្តិ)៖ បានប៉ាស់ស្ពរ៍បានអីហើយ!!

ខ៖ បងឯងហើយបងណារី។

ក៖ ហ្នឹងហើយ!!

(មិត្តភក្តិ)៖ ទៅជាមួយគ្នា!!

ខ៖ ទៅជាមួយគ្នាហើយទៅវគ្គមុនទៅ!!វគ្គមុនមុនញ៉ុមហើយមើលទៅហ្នំ!!

ក៖ អត់ទេបើសិនជាអ្នកមីងរៀបចំខ្លួនឥឡូវទាន់តើ!!

ខ៖ ញ៉ុមចង់ទៅជាមួយចយអីក្រោយ!!ចយនិយាយថាចង់ទៅ ចង់ទៅរៀនរវល់តែខាន
អាទិត្យមុនចយអត់ទៅហ្នឹង ចយអត់ទៅតើ!!ចយអាលែងឧបគេហ្នឹង គ្នាអត់ដែរហាំគ្នា
ធម្មតាគ្នាម៉ូយហៅទៅណោះទៅណោះ!!

(មិត្តភក្តិ)៖ ហ្នឹងហើយអត់អីទេ!!ចុះយើងយូរៗខានម្តងអត់អីទេ!!ញ៉ុមខានដែរហ្នឹងពេលខ្លះ!!

ក៖ ចាំអញ្ចឹងអ៊ំចូលដល់យាយវិញម្តង មិញយាយម៉េចខ្លះទៀត?

ខ៖ យាយ យាយៗក៏គាត់ស្រលាញ់ចៅខ្លាំងណាស់ដែរ!!
យាយវិញនៅជាមួយយាយញ៉ុមធ្លាប់នៅជាមួយគាត់អត់ដែលខ្វះហូប!!

ក៖ចាំ!!

ខ៖ យាយគាត់ប៉ុនធ្វើម្ហូប បង្អែមមិនចេះដាច់ទេបង!!

(មិត្តភក្តិ)៖អោយថៅ!!

ខ៖ ធ្វើអោយថៅហូប ហើយមុនកាលបែកអាពតហ្នឹង មុនឆ្នាំ៧៥(១៩៧៥)ហ្នឹងម៉ែញ៉ុមនៅយើងម្តុំព្រែកថីនេះ!! ហាម៉ែមិនមែននៅម្តុំព្រែកថីទេ ម៉ែនៅម្តុំព្រែកខ្សេវ ។

ក៖ចាំ!!

ខ៖ នៅជំនាន់អាពតហាំ ហើយយាយនៅក្រាំងយ៉ូវ យាយគេជំលៀសទៅនៅក្រាំងយ៉ូវ!!

(មិត្តភក្តិ)៖ ហ៊ីក្រាំងយ៉ូវ!!

ខ៖
ចាំពេលហ្នឹងពេលសង្គ្រាមវ៉ៃគ្នាមុនឆ្នាំ៧៥(១៩៧៥)ហ្នឹងហើយដល់ពេលហ្នឹងគេមិនជំលៀសទៅនៅក្រាំងយ៉ូវទៅ ម៉ែជំលៀសទៅដែរទៅនៅកោះខែល ពីកោះខែលមកវិញមកនៅត្រឹមព្រែកខ្សេវ!!យើងកន្លែងហ្នឹងសុទ្ធតែទាហានសុទ្ធតែអីអត់កមានបានមកលេងកន្លែងហ្នឹងទេណាស់!!នៅណោះក្រោមហ្នំនៅម្តុំព្រែកខ្សេវហ្នំ!!ហើយយាយញ៉ុមនៅក្រាំងយ៉ូវហើយបងអើយញ៉ុមនៅទូចយាយធ្វើនំគ្រាបបាយ នំកូរ ហើយគាត់បបួលញ៉ុមដើរតាំងពីក្រាំងយ៉ូវ ទូលនំយកមកអោយម៉ែហាំ!!

ក៖ ឆ្ងាយណាស់អ៊ំហីក្រាំងយ៉ូវហ្នឹងហី?

ខ៖ ឆ្ងាយ ក្រាំងយ៉ូវមិនមែនធម្មតាទេគឺឆ្ងាយ!!

(មិត្តភក្តិ)៖ឆ្ងាយសឹងតែទទឹមទន្លេបាទីអីនេះណោះ!!

ខ៖ ហើយញ៉ុមចេះតែដើរតាមគាត់ហើយ យាយញ៉ុម គាត់អានិតម៉ែញ៉ុមកូនច្រើនហើយគាត់អត់ហាំ!!

ក៖ចាំ!!

ខ៖គាត់អត់ជំនាន់អាពត!!

ក៖ ហាំហើយពេលហ្នឹងធ្វើនំបានទៀតនៅក្នុងជំនាន់ប៉ុល ពតហ្នឹង?

ខ៖ នៅជំនាន់ប៉ុល
ពតហ្នឹងយើងមិនទាន់ចូលរួមសាមគ្គីណាយើងនៅដាំបាយហូបដោយខ្លួនហូបដោយខ្លួនកាលហ្នឹងហាំ!!

(មិត្តភក្តិ)៖ នៅហ្នឹងធូរ!!

ខ៖ តែគ្រាន់តែធ្វើការម៉ែធ្វើការនៅក្នុងរួម
ដូចថារួមដូចញ៉ុមនិយាយក្នុងក្រុមអញ្ចឹងណាស់!!អាពតដាំរួមគ្នាអីអញ្ចឹងទៅណាស់!!

(មិត្តភក្តិ)៖ នៅនេះធូរ!១

ខ៖ ចាំហើយដល់ហើយយាយគាត់នៅក្រាំងយ៉ូវណោះ គាត់មិនស្រុកសំបូរស្គរ
សំបូរអង្ករដំណើប!!

ក៖ចាំ!!

ខ៖សំបូរអីអញ្ចឹងណាស់!!គាត់ធ្វើនំធ្វើបង្អែម គាត់អានិតកូនគាត់នោះ!!
តោះទៅលេងម៉ែង៉ែងអញធ្វើត្រាបបាយ
ធ្វើត្រាបបាយទូលត្រាបបាយមិនត្រឹមតែទូលតែត្រាបបាយទូលទាំងអង្ករទាំងអីយកមកអោយម៉ែញ៉ុមចាំ!!យើងជិតបែកឆ្នាំ៧៥(១៩៧៥)ហ្នឹងអត់ណាស់បង!!!

ក៖ចាំៗ!

ខ៖ហើយបងយើងបែកឆ្នាំ៧៥(១៩៧៥)ហ្នឹងហើយរឹតតែអត់ទៀត!!

ក៖ ហ៊ិពេលហ្នឹងវេទនាណាស់!!

ខ៖ ពេលហ្នឹងយើងធ្វើស្រូវធ្វើអង្ករអត់ទាន់បានហូបទេកាលហ្នឹងហ្ន៎!!

ក៖ចាំ!!

ខ៖បានអត់មួយសារទៀត ចូលរួមទៀតយ៉ាប់វេទនា
និយាយទៅយ៉ាប់តែពេលក្នុងជំនាន់អាពតហ្នឹងទេ!!

ក៖ ហ្នឹងអ្នកណាគេក៏អញ្ចឹងដែរអុំណោះ?

ខ៖ ចាំ!!យ៉ាប់យើងដាច់បាយដាច់ទឹកស្លាប់គ្រប់គ្នាមកអស់មួយកំនរហើយ ហ្នឹងហៅថាយាយគំនិតកើតម៉ែគំនិតកើតចេះនៅលាក់លៀមអង្ករអោយកូន បបរខ្លះអីខ្លះទុកអោយកូនហូបហាំ!!ចំនែកអ្នកផ្សេងនៅជិតៗហ្នឹង អ្នកផ្សេងនៅជិតខាងយើងគេអត់ជាងយើងបងអើយបេះព្រលិតបេះអីបបរអោយកូនហូបដូចជ្រូកអីចឹង ហើយហ្នឹងយាយយើងមានគំនិតហើយមានស្គរទាំងឡាំងអាឡាំងគ្រាប់យើងហ្នឹងហាំ!!

ក៖ ចាំ!!ហើយលាក់ម៉េចទៅអ៊ំអោយផុតពីភ្នែកគេអ៊ំ?

ខ៖ លាក់ជិតតើ!! ជីកដីកប់!!ឡាំងហ្នឹងវាអត់ចូលទឹក ឡាំងគ្រាប់យើង កេសគ្រាប់នោះបង!!

ក៖ចាំ!!

ខ៖កេសគ្រាប់យើងមិនគន្លឹសវាមិនដាក់ជិតកឹបជាប់ហាំ!!ក៖ហ៊ឺ!!ខ៖ហើយដាក់ស្គរពេញៗឡាំងហ្នឹងទៅ ប្អូនដប់ឡាំងអីអញ្ចឹងទៅ!!

ក៖ ចំ!!

ខ៖ ជីកដីកប់ណាស់ !!

ក៖ អូយឆ្លាតណាស់!!

ខ៖ ជំនាន់អាពតយាយញ៉ុមឆ្លាតណាស់!!បានញ៉ុមនិយាយថាម៉ែញ៉ុមមិនដល់យាយញ៉ុមដែរ!!លុយហាលុយ គាត់មានលុយច្រើនអញ្ចឹងគាត់ គាត់ប៉ុនទុកដាក់ម៉ង!!

(មិត្តភក្តិ)៖ មានរូបថតគាត់ទេ?

ខ៖ ណោះមានរូបថតគាត់នៅផ្ទះម៉ែ !!

(មិត្តភក្តិ)៖ នៅរូបថតគាត់!!

ខ៖ នៅរូបគាត់ គាត់មានលុយអញ្ចឹងគាត់ដូចគាត់ដឹងថាស្រុកគេជិតលែងចាយលុយអញ្ចឹងហាំ ពេលយើងមុនឆ្នាំ៧៥(១៩៧៥)គេមិនចាយ !!

ក៖ចាំ!!

ខ៖ដល់ឆ្នាំ៧៥(១៩៧៥)ម៉ងបានគេអត់ចាយម៉ងបង!!

(មិត្តភក្តិ)៖ ហ្នឹងហើយ!!

ខ៖ ដល់ពេលអាឆ្នាំ៧៥(១៩៧៥)ម៉ងបានឈប់ចាយពិបតែម្តង!!យាយញ៉ុមទិញស្ករ!!

ក៖ ទាំងអស់!!

ខ៖ លុយគាត់ទិញស្ករទុកតែបន្តិចបន្តួច ពេលគេលែងចាយលុយយាយនៅលុយតិចហ្នឹង!!

ក៖ ហោង!!

ខ៖ អ្នកខ្លះនៅលុយទាំងបាវទាំងអស់!!

ក៖ ហ្នឹងហើយ!!អាខ្លះវិញមិនបាច់ទេ!!

ខ៖ចាំ!!គាត់ទិញស្ករដាក់ឡាំងហើយដល់ពេលហើយគាត់មកនៅយើងហ្នឹងម្តុំជិតវត្តហ្នឹង
បកពីក្រាំងយ៉ុវមកវិញហាំ!!ហ្នឹងមកគេប្រមូលចូលរួមមកស៊ីបាយរួមហ្នឹងពេលហ្នឹងហាំ!!

ក៖ អ៊ីចឹងចោលស្ករចោលអីនៅណោះហើយអញ្ចឹងអំណោះអ៊ីចឹង?

ខ៖ ហ៊ឺដឹករទេះ យកមកជីកដីកប់នៅយើងឃុំសិត្បូហ្នឹងហិ!!

ក៖ហ្ហ៎!!

ខ៖ ប៉ុនយើងនៅអាកន្លែងម្តុំផ្ទះម៉ែញ៉ុមសព្វថ្ងៃហ្នឹងភូមិសិត្បូហើយយាយគាត់នៅហ្នឹងហាំ!!

ក៖ចាំ!!

ខ៖
នៅកន្លែងផ្ទះម៉ែនេះនៅអាខាងណោះវត្តបន្តិចហ្នឹង!!ក្នុងហ្នឹងក៏ឃុំសិត្បូនៅក្នុងជំនាន់អាពតហាំ!!

ក៖ចាំ!!

ខ៖ហើយយាយញ៉ុមជីកដីកប់ស្ករហ្នឹងអ្នកណាដឹង
ចង់ហូបអីពេលយប់គាត់បបរអោយចៅគាត់ហូប អត់ចេះអត់ទេ
អ៊ិចឹងបានយាយញ៉ុមមានគំនិតណាស់ ហើយអំបិលគាត់អត់កមានអត់ចេះហូបទុកហូបយើង
គ្រាន់តែបែកអាពតហើយភ្លាមបងហាំអត់មានអំបិលហូបទេ កាលជំនាន់
ជំនាន់អាពតប៉ុន្មាន៣ឆ្នាំ ប៉ុន្មានឆ្នាំហ្នឹង!!

ក៖ ៣ឆ្នាំ ៨ខែ!!

ខ៖ ពីឆ្នាំ៧៥(១៩៧៥)!!

(មិត្តភក្តិ)៖ គាត់ទុកអំបិលបានទៀត!!

ខ៖ យាយញ៉ុមមានអំបិលអត់មានអត់អំបិលអោយកូនចៅហូបទេបងអើយ!!

ក៖ហេងខ្លាំងណាស់!!

ខ៖ ជំនាន់យាយញ៉ុម យាយញ៉ុមគំនិតមែនទែន ម៉ែញ៉ុមក៏គំនិតមិនដល់ម៉ែញ៉ុមដែរ!!

ក៖ ហ្នឹងហើយ គំនិតមួយនេះធំខ្លាំងណាស់អ៊ំណាស់!!

ខ៖ ហ្នឹងហើយចាំធំខ្លំាងម៉ងហាំ!!សឹងថាគ្មាន១០រកអត់បានថាដូចយាយញ៉ុមមួយហ្នឹងហាំ!!

ក៖ ១០០០សឹងក៏អត់មានមួយដែរនេះហិ!!ចេះបានជីកដីកប់ស្ករនៅក្នុងជំនាន់ដែលវេទនា!!

ខ៖ចាំ!!

ក៖បានហូបទាំងអស់គ្នា!!

ខ៖ ហើយគ្មានអ្នកណាគេដឹងទេ គាត់ហូបទាល់តែអស់!!

ក៖ ប៉ុន្មានឆ្នាំហ្នឹង ហ៊ីច្រើន!!

ខ៖ ចាំ!!

ក៖បានច្រើនឆ្នាំដែរ!!

(មិត្តភក្តិ)៖ ហេស្កុរប្រហុកអីកប់ក្នុងជីវីតតែល្អ!!

ខ៖ ជីកដីកប់!!

ក៖ អោយតែជិតៗពីដីហ្នឹង!!

ខ៖ កុំអោយតែគេដឹងទៅ ចង់ហូបផ្ទះយើងវាមិនមែនអង្គុយតែតាមដាន២៤ម៉ោង វាតាមដែរ វាតាមបង្កាត់ភ្លើងយប់អីហ៊ុយៗឆ្លបវានេះដែរ ប៉ុន្តែយើងស្កុរមានឪកាសចាំនេះទៅ បើអត់ទេត្រឹមតែថាលិតហូបក៏វាមិនអីដែរ!!អោយតែមាន!!

ក៖ ហ្នឹងហើយ!!

ខ៖ គេខ្លះគេមិនមានស្កុរសោះម៉ងហាំ!!

ក៖ ទោះម៉េចក៏បានផ្អែមៗ អំបិលប្រៃៗមកដែរ !!

ខ៖ហ្នឹងហើយ!!

ក៖ រស់បណ្តោយ!!

ខ៖ រស់ម៉ង!!

ក៖ចាំ!!អ៊ីចឹងអ៊ំសំរាប់ដល់តាវិញ តាខាងម៉ែគាត់ឈ្មោះអីគេវិញអ៊ំ?

ខ៖ ហ៊ឺតាខាងម៉ែគាត់ស្លាប់តាំង តាំងពីអាយុ៣០ជាងហ្នុំ!!

ក៖ហើយម៉េចអញ្ចឹង?លឿនម្ល៉េះ?

ខ៖ គាត់ទឹកនោមផ្អែម!!

ក៖ ទឹកនោមផ្អែមតាំងពី៣០ជាង?

ខ៖ ចាំ!!តាំងពី៣០ជាង!!

(មិត្តភក្តិ)៖ ស្រុកពីដើមទឹកនោមផ្អែមអត់ដែលដឹងទេនេះ!!

ខ៖ ម៉ែញ៉ុមគាត់ទូចៗគាត់ស្លាប់ចោលទៅហាំ!!

កៈហើយម៉ែមានប្រាប់ថាតាឈ្មោះអីទេអ៊ំ?

ខៈ តា តាកៅ!!

កៈតាកៅ ចាំត្រកូលគាត់ទេ?

ខៈ អត់ស្គាល់ទៀតស្គាល់ត្រឹមតា!!

កៈ ចុះដល់ពេលត្រកូលម៉ែត្រកូលអីគេវិញ?

ខៈ កៅជាហ្នឹង!!

កៈ ហ្ហូហ្នឹងហើយ !!

ខៈ ឈ្មោះតាហ្នឹង!!

កៈអញ្ចឹងយកឈ្មោះតាទេអ៊ីចឹង!!អត់ដាក់ឈ្មោះតាគាត់ណោះទេ!!

ខៈយកឪពុកគាត់ហ្នឹង ហ្នឹងឪពុកម៉ែញុំមហើយកៅហ្នឹងហាំ!!

កៈចាំប៉ុន្តែម៉ែរបស់អ្នកមីងគាត់អត់បានឈ្មោះតាយកមកដាក់ត្រកូលទេតែដាក់ឪពុក!!

ខៈចាំដាក់ឪពុក!!

កៈ ចាំអញ្ចឹងពេលគាត់ស្លាប់ឆ្នាំណាវិញអ្នកមីងចាំទេ?ម៉ែនៅប៉ុន្មានឆ្នាំបាននេះ?

ខៈបើម៉ែ បើម៉ែគាត់និយាយប្រាប់ទេណាស់!!

កៈចាំ!!

ខៈឪពុកគាត់ស្លាប់តាំងពីគាត់ទឹមអាយុទឹមតែ១២ ១៣ឆ្នាំ!!

(មិត្តភក្តិ)ៈហ្ហូយូរ!!

ខៈចាំ!!

កៈ
និយាយទៅដឹងតែឆ្នាំគាត់អាយុប៉ុណ្ណឹងគាត់ដឹងដែរថាយាយអាយុ៨០ឆ្នាំហើយ!!អញ្ចឹងពេលប៉ា
ស្លាប់!!

ខៈយាយបើយាយទឹមតែស្លាប់ថីមិនដឹង បើតាស្លាប់យូរណាស់ហើយ!!

កៈចាំ!!

ខៈស្លាប់តាំងពីគាត់មិនទាន់ការហើយយើងមិនទាន់កើត
អ៊ិចឹងពេលហ្នឹងបើគាត់មិនទាន់ការផង!!

កៈហ្នឹងហើយយូរណាស់ហើយ!!

ខៈ យូរហាំ!!

កៈ ចុះម៉ែមានប្រាប់ថាតាអ្នកស្រុកមកពីណាទេអ៊ំ?

ខៈ តា និយាយទៅដូចស្រុកកំនើតដូចស្រែដូចជាទំនង!!ស្រុកស្រែតាញ៉ុម!!

(មិត្តភក្តិ)ៈ អត់ចាំ!!

ខៈ
ហ្នឹងហើយអត់ចាំតែគាត់មានបងប្អូនគាត់មីងមាយើងនៅស្រែហ្នឹងស្រែអាយោងស្រែអីហ្នឹង
ណាស់!!

កៈស្រែអាយោង?

ខៈ ហ្នឹងហើយគាត់!!

កៈ ស្រែអាយោងនៅណាវិញទៅអ៊ំ?

ខៈ នេះនៅយើងនេះ!!

(មិត្តភក្តិ)ៈ ស្រែអាយោងនៅយើងនេះអីណោះទេ ក្រែងនៅនេះមានឈ្មោះស្រែអាយោងដែរ!!

ខៈ មានតើបង!!

ក៖ហ្ហ៎នៅស្អាង!!

ខ៖ នៅខាងលិចយើងនេះ មិនមែនដូចយើងទៅ !ហ៊ីញ៉ុមមិនដឹងហៅថាម៉េចដែរទេ!!!

ក៖តែនៅក្នុងស្រុកស្អាងហា៎!!

ខ៖ នៅតាកែវណោះទេហេ ស្រែអាយោងហា៎!!

(មិត្តភក្តិ)៖ ស្រែអាយោងញ៉ុមនៅខាងហ្នឹង!!ហ្នឹងស្រែអាយោងហ្នឹងហេ??

ខ៖ ចា៎ហ្នឹងហើយនៅម្តុំហ្នឹង!!

ក៖នៅម្តុំណាម៉ែស្រែអាយោង?

(មិត្តភក្តិ)៖
ស្រែអាយោងផ្លូវទៅសៀមរាបផ្លូវទៅទន្លេបាទីយើងហ្នឹង!!ទៅហើយមកឯកើតហ្នឹងមក!!

ខ៖ ហ្នឹងហើយ ហ្នឹងហើយ!!

ក៖ហ្ហ៎!!

ខ៖ផ្លូវមកពីទន្លេបាទីហ្នឹង!!

ក៖ហ្ហ៎ផ្លូវតែមួយមកពីណោះវិញមិនមែននៅកោះគរណោះ!!

ខ៖ គាត់នៅស្រុកកំនើតគាត់នៅហ្នឹងមិនដឹងអីទេ តែគ្រាន់តែគាត់ថា!!

(មិត្តភក្តិ)៖ មកពីស្រែអាយោង?

ខ៖ ហ្នឹង!!

ក៖ ហ្នឹងហើយ!

ខ៖ យាយញ៉ុមគាត់នៅកោះខែលទេ ស្រុកកំណើតរបស់គាត់ហា៎!!

ក៖ហ៊ឺ!!

ខ៖ហ្នឹងយាយ
យាយប្រពន្ធតាហ្នឹងហាំ!!ហើយដល់ហើយបានតាគាត់ទៅស្ដីពីកោះខែលហ្នឹងមក!!បានមក
នៅហ្នឹង ទៅនៅក្រោមវត្តឈ្វងលៀបហ្នឹង មិនដឹងស្រុកកំណើតគាត់ឬក៏អី
ប៉ុន្តែឃើញជូនតាគាត់វានៅស្រែហាំ!!

ក៖ចាំ!!

ខ៖ ថាក្រែងលោរម្ដាយគាត់ឪពុកគាត់អីក្រែងនៅស្រែក៏មិនដឹង។

ក៖ហើយម៉ែមានដែលប្រាប់អីថាតាម៉េចៗអីទេអ្នកមីង?

ខ៖ តាមគាត់និយាយតាគាត់
តាមគាត់និយាយតាគាត់ប្រវត្តិគាត់ហ្នឹងគាត់អ្នកមើលគោដែរ!!គាត់អ្នកលែងគោដែរ ដូចថា!!

(មិត្តភក្តិ)៖ គ្រូគោដែរ!!

ខ៖ ចាំ!!ហើយគាត់ដើរម៉ាស៊ីនភ្លើងទៀតតាញ៉ុមណាស់!!
តាដែលគាត់ស្លាប់៣០ជាងហ្នឹងណាស់!!

ក៖ចាំ!!

ខ៖ម៉ែថាគាត់មានម៉ាស៊ីនភ្លើង មានម៉ាស៊ីន ម៉ាស៊ីនអីទេ
ម៉ាស៊ីនកិនស្រូវទេអី!!មិនមែនម៉ាស៊ីនភ្លើងទេ ម៉ាស៊ីនកិនស្រូវ!!

ក៖ ដើរកិនតាម!!

(មិត្តភក្តិ)៖ ជំនាន់ហ្នឹងមានទឹកនោមផ្អែមដែរណោះ?

ខ៖មាន !!គាត់មាន ទឹកនោមផ្អែមគាត់ឈឺឆាប់ស្លាប់ទៀតណាស់!!ដូចយើងសម័យហ្នឹង
ដូចវាអត់មានអីទប់ស្កាត់ណាស់!!

ក៖ចាំទៅតែម្ដង!!

ខ៖ពីដើមកើតលឿនម៉ង!!អត់បានរស់យូររាប់ឆ្នាំទេ!!

(មិត្តភក្តិ)៖ រោគហ្នឹងយើងអត់ដែលដឹងណាស់!!

ខ៖ យើងអត់ដែលដឹងណាស់ ដល់ពេលកើតកើតឆាប់ម៉ង!!

ក៖ចាំ!!

ខ៖ដូចថាមើលអត់ទាន់អញ្ចឹងម៉ងណាស់!!

ក៖ហ៊ី!!

ខ៖ហើយយើងសម័យមុនដូចថាយើងអត់មានថ្នាំទប់ស្កាត់ដូចឥឡូវណាស់!!

ក៖ ហ្នឹងហើយ!!

ខ៖ ឥលូវបើទឹកនោមផ្អែមខ្លាំងវាមានថ្នាំចាក់ថ្នាំអីណាស់បង!!

(មិត្តភក្តិ)៖ ហ្នឹងហើយ!!

ក៖ហ្នឹងហើយ!!ចាំ!!

ខ៖ ហើយកាលពីមុនអត់!!

(មិត្តភក្តិ)៖ ហើយគាត់អោយហាត់ប្រាណ ហាត់ប្រាណជាឯងម៉ង!!!

ក៖ហើយបើមុនអីបន្តិចឆាប់ក្លាយណាស់!!

ខ៖ ក្លាយណាស់
គាត់ទឹកនោមផ្អែមម៉ែថាទឹកនោមគាត់ដល់ពេលនេះមែនទែនទៅនោមមកខាប់ម៉ងវា!! តា។

ក៖ ចាំអ៊ិចឹងអ៊ំចូលដល់ខាងឪពុកវិញម្តងតាឈ្មោះអីគេវិញខាងឪពុក?

ខ៖ តាឈ្មោះតាម៉ី!

ក៖ អត់ចាំត្រកូលគាត់ទេហី?

ខ៖ ស្ងៀ!!

កះស៊ូ ម៉ី?ខះចាំ!!កះអ៊ំកើតទាន់គាត់ទេ?

ខះ កើតទាន់។

កះទាន់ហេ !!តែគាត់ស្លាប់ប៉ុន្មានឆ្នាំហើយអ៊ំ?

ខះ ស្លាប់៧៩(១៩៧៩)ដែរគាត់ស្លាប់មុនញ៉ុមការផង!!

កះ តែបែកមកហើយហើយ?

ខះ បែកភ្លាម!! បែកភ្លាម!!

កះហើយម៉េចអ៊ិចឹង ដល់ពេលតស៊ូបានហើយដល់ពេលនេះអត់ព្រមបានទៀត!!

ខះ គាត់ចាស់ ធ្វើម៉េច បើនៅក្នុងជំនាន់អាពតអាយុយើងមិនទាន់អស់
គាត់ចាស់ហើយគាត់ធ្វើស្អី។

កះ ហ្ហ៎ គេអ៊ំដល់ពេលអ្នកដែលចាស់នៅក្នុងជំនាន់ប៉ុល ពតគេអត់អោយធ្វើអីដែរហេ?

ខះ គេអត់អោយធ្វើអីដែរហ្នឹង!!នៅតែផ្ទះហ្នឹង!!

កះ តែគេអត់យក!!

ខះ គេមានយកគាត់ទៅធ្វើអីកើត!!មនុស្សចាស់
នៅតែផ្ទះអញ្ចឹងទៅ!!ដល់ពេលបែកអាពតហើយបានគាត់ស្លាប់ គាត់ចាស់ស្លាប់ហ្នឹងហាំ!!

កះ អាយុប៉ុន្មានពេលហ្នឹងអ៊ំ?

ខះ ញ៉ុមអត់ចាំទេតា!!ដឹងតែគាត់ចាស់ខ្លាំម៉ងហាំ!!

កះ ចាស់ក្បែរ១០០?

ខះ ដឹងតែគាត់ចាស់ចង់ក្បែរ១០០មែនហ្នឹង!! គាត់ចាស់ខ្លាំងមែនទែន ចាស់!!

កះ តែគ្រាន់តែដឹងថាស្លាប់នៅក្នុងឆ្នាំ១៩៧៩!!

(មិត្តភក្តិ)ះ ទុំជ្រុះម៉ង!!

កៈ អ៊ំអនុស្សាវរីយ៍ជាមួយតាមើលអ៊ំនិយាយប្រាប់បន្តិចមើលម៉េចដែរ តាខាងឪពុក?

ខៈ តាខាងឪពុកញ៉ុមគ្រាន់តែចាំថាពេលញ៉ុមនៅទូចៗណាស់!!

កៈចាំ!!

ខៈ គាត់ច្រើនតែមកយកចៅទៅលេងជាមួយ តាហា៎!!

(មិត្តភក្តិ)ៈ ចាស់ៗពីដើមគាត់តែអញ្ជឹង!!

ខៈ ចាំ!!តាយកចៅទៅ ហើយគាត់ដុតភ្នក់គោហ្ន៎!!

(មិត្តភក្តិ)ៈ ហ្នឹងហើយ ហ៊ុយ!!

ខៈ ហើយញ៉ុមទៅដេកជាមួយ ហ៊ុយអាភ្នក់គោហ្នឹង!!ហើយជើងដំបៅអីហ្នឹង ហើយតាញ៉ុមហា៎ តាខ្លះខ្ជិលណាស់ ហើយតាញ៉ុមហា៎ដាំទឹកម្ទូរ យើងជំនាន់ហ្នឹងហា៎ដាំអាទឹកម្ទូរយើងអាទឹក!

(មិត្តភក្តិ)ៈ ស្លឹកអំពិល!!

ខៈអាទឹកស្លឹកអំពិលហ្នឹងបងគាត់បូតហា៎យកដាំ ញ៉ុមចាំដំបៅញ៉ុមប៉ុនហ្នឹង នៅទាល់តែឥឡូវហា៎!!(ស្លាបស្នាម)!!តាញ៉ុមយកមកដុះលាងរោយអោយស្អាតអ៊ីចឹងទៅរោយអាថ្នាំយើងយើងអាប៉េសាលីនអាម្សៅៗហ្នឹង!!

កៈចាំ!!

ខៈគោរោយអោយឆាប់ជាទៅ!!ហើយអើយនិយាយទៅតាញ៉ុមក៏ស្លូត!!

កៈ ចុះយាយវិញ យាយឈ្មោះអីគេវិញអ៊ំ ខាងឪពុក?

ខៈ យាយឈ្មោះយាយខាត់។

កៈហ្ន៎មិញឈប់សិន តាមកពីស្រុកណាវិញអ៊ំ?

ខៈ អត់ដឹងទេនេះ!!

កៈ អត់ចាំដែរហោ?

ខ៖ ស្រុកគាត់នៅហ្នឹងដែរហ្នឹង!!

ក៖ នៅព្រែកថីហ្នឹងដែរហ្នឹងអ៊ំណេះ?

ខ៖ ចាំ!!

ក៖ ចាំចុះយាយម៉េចយាយខាត់ហេ?

ខ៖ ចាំ បើយាយខាត់បានមកពីស្រែទៀតហើយ!!

ក៖ មកពីស្រែណាវិញ?

ខ៖ ស្រែ មិន ម្តុំស្រែអាយោងដែរហ្នឹងស្រែម្តុំហ្នឹងៗណាស់!!

ក៖ហ្អូចាំ!!

ខ៖ព្រោះអីដឹងតែយាយស្រុកស្រែហ្នឹងហើយ!!

ក៖ត្រកូលគាត់អីគេវិញអ៊ំ?

ខ៖ អត់ស្គាល់!!

ក៖ ស្គាល់តែឈ្មោះទេ។

ខ៖ ស្គាល់តែឈ្មោះយាយញ៉ុមហ្នឹង ស្លៀកតែសំពត់ចងក្បិនទេតូច!!គាត់នៅស្រុកស្រែហាំ!!

ក៖ចាំ!!

ខ៖គេហៅគាត់កូននាង១២ កូននាង១២ គាត់កូនច្រើនណាស់ គាត់តែទូចទេ
យាយញ៉ុមហ្នឹងហាំ!!

(មិត្តភក្តិ)៖ អ្នកទូចខ្លះកូនច្រើន!!

ខ៖ ចាំទូចរាងគាត់ថាទូចម៉ងហ្នឹងហាំ!!

ក៖ ហើយអ៊ំកើតទាន់គាត់ដែរ ហើយឃើញមុខគាត់ដែរហេ?

ខ៖ឃើញ ស្លៀកតែសំពត់ចងក្បិនទេ!

ក៖ចាំ!!

ខ៖នៅក្នុងស្រុកក្នុងភូមិមានតែយាយញ៉ុមមួយទេ ស្លៀកសំពត់ចងក្បិនហ្នឹង
គាត់ទូចហ្នុំគាត់ស្លៀកសំពត់ចងក្បិនគាត់ទូចស្អាតដល់ហើយ!!

ក៖ ចាំហើយពាក់អាវបំពង់ឬក៏ពាក់អាវអីអ៊ំ?

ខ៖ គាត់ពាក់អាវ និយាយទៅគាត់ចាស់ពីដើម គាត់អាវ !!

(មិត្តភក្តិ)៖ច្រើនតែអាវបំពង់។

ខ៖ ហ្នឹងច្រើនតែអាវបំពង់ហ្នឹង ច្រើនគាត់ច្រើនស្លៀកសំពត់ខ្មៅអីចងក្បិនហ្នឹងណាស់!!

ក៖ចាំ!

ខ៖មើលទៅស្អាតគាត់!!

ក៖អើយអនុស្សាវរីយ៍ជាមួយយាយ។តែអ៊ំអត់ទាន់តែតាខាងម្តាយមួយទេ?

ខ៖អត់ទាន់តែទាខាងម្តាយដោយសារតែតាខាងម្តាយគាត់ស្លាប់តាំងយើង
តាំងពីម៉ែញ៉ុមនៅទូចដែរ!!

ក៖ហើយយាយ យាយខាងឪពុកហ្នឹងស្លាប់បាត់ហើយអ៊ំណេះ?

ខ៖ យាយខាងឪពុកស្លាប់ក្រោយតាទេ តាស្លាប់៧៩(១៩៧៩)!!

ក៖យាយស្លាប់ប៉ុន្មានវិញ?

ខ៖ យាយស្លាប់អើរ ៨០ជាងហើយយាយហ្នុំ!!

ក៖ គាត់ស្លាប់ហ្នឹងអាយុប៉ុន្មានវិញអ៊ំ?

ខ៖ ចាស់ដែរហើយហ្នឹង គាត់សុទ្ធតែចាស់ៗហើយហ្នឹងបានស្លាប់!!

ក៖តែអត់ចាំឆ្នាំ?

ខ៖ អត់ចាំ !!

ក៖អាយុគាត់អី?

ខ៖ អាយុគាត់ញុំមអត់ចាំទេ!!ចាំតែម៉ែ!!

ក៖ចាំអញ្ចឹងអ៊ំបងប្អូនអ៊ំទាំងអស់គ្នាហ្នឹងមានធ្លាប់អ្នកណាគេធ្លាប់ទៅរស់នៅប្រទេសខាងក្រៅទៅណាទីនីទេ?

ខ៖អត់!!

ក៖ចុះមានអ្នកណាគេធ្លាប់ទៅធ្វើការនៅថៃនៅអី?

ខ៖អត់!!

ក៖នៅតែស្រុកខ្មែរយើងហ្នឹងទេហេ?

ខ៖ធ្លាប់ប្អូននោះគេទៅប៉ុន្តែមកវិញហើយ។

ក៖ទៅណាវិញ?

ខ៖ គេទៅនៅថៃមួយរយៈដែរហ្នឹង !!

ក៖ហ្អ៎!!

ខ៖ហ៊ីទៅរកវាយ៉ាប់រកដែរហ្នឹងណាស់!!ដូចវាធ្វើខាងជាងផ្ទះជាងអីអញ្ចឹងណាស់!!ខាងសំណង់អីអ៊ីចឹងណាស់!!

ក៖ ហ្អ៎ចាំ ដូចពូផល្លីពេលមុនដែរហ្នឹងហាំ?

ខ៖ ហ្នឹងហើយ ហ្នឹងទៅធ្វើអញ្ចឹងទៅ ទៅធ្វើប្រហែលប៉ុន្មានទេប្រហែលមួយឆ្នាំហ្នឹង!!

ក៖ ហ្នឹងហើយ!!ទោះម៉េចក៏មិនស្រួលស្រួលដូចស្រុកខ្លួនឯងដែរ!!

ខ៖មិនស្រួលស្រួល!!

កះចាំអរគុណអ៊ំច្រើនដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិជូនតាក៏ដូចជាអ៊ំខ្លះៗផងដែរ ហើយអ្វីទាំងអស់ហ្នឹងកូនចៅរបស់អ៊ំគាត់នឹងបានស្តាប់ហើយនឹងទុកទៅថ្ងៃខាងក្រោយណាស់អ៊ំ!!!

ខះចាំ។